# ព្រឹត្តិបត្រ នារីរតនៈ

# NEARY RATTANAK NEWSLETTER

២០១៥. លេខ៥២ ឆ្នាំទី៩



## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ផ្តល់ទ្រនាប់លើកទឹកចិត្ត ដល់សិស្សនិទ្ទេស A ចំនួន ១០៨ នាក់

ចេញផ្សាយពីនាយកដ្ឋានព័ត៌មាន នៃក្រសួងកិច្ចការនារី
Organized by Information Department of Ministry of Women's Affairs
គេហទំព័រ: www.mowa.gov.kh

ក្រសួងកិច្ចការនារី

## គណៈកម្មការត្រួតពិនិត្យ

-លោកជំទាវ **ខេង សំវ៉ាដា** រដ្ឋលេខាធិការ

-លោកជំទាវ **ឡុង សុផល្លី** អនុរដ្ឋលេខាធិការ

-លោកស្រី **យិន សារ៉ាត់** ប្រធាននាយកដ្ឋាន

## គណៈកម្មការនិពន្ធ

-លោកស្រី **អ៊ុង ខេមរា**

-លោកស្រី **ប៉ែន គន្ធា**

-លោក **ប៉ែន ជា**

-លោកស្រី **តែ សុខខេង**

## រៀបរៀង និងក្រាហ្វិចកុំព្យូទ័រ

-លោកស្រី **ប្រាក់ សោភា**

-លោក **ផុន ពុធបូរី**

-កញ្ញា **ទឹម ពេជ្រកេសរ៉ី**

# មាតិកា


- កិច្ចប្រជុំកំពូលអង្គការសហប្រជាជាតិ.................................០១
- ចំណុចសំខាន់ៗសម្រាប់ការចូលរួមមតិរបស់...................០៣
-កម្មវិធីផ្សព្វផ្សាយជាផ្លូវការផែនការយុទ្ធសាស្ត្របញ្ច្រាប.......០៥
-សិក្ខាសាលាបញ្ចប់គម្រោងបញ្ជ្រាបយេនឌ័រដំណាក់..........០៧
-កម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍.......................................០៨
-សិក្ខាសាលាផ្សព្វផ្សាយស្ដីពីការអនុវត្តគម្រោង.....................០៩
-សិក្ខាសាលាស្ដីពី ការអភិវឌ្ឍន៍សមាគមអាជីវកម្មស្ត្រី..........១០
-សិក្ខាសាលាស្ដីពី " យេនឌ័រ និងគោលនយោបាយ....... "....១១
-យុវនារីនិទ្ទេស A.............................................................១២
-សន្និសីទពិភពលោក ស្ដីពី ស្ត្រី........................................១៩
-សន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ានស្ដីពី ស្ត្រី......នៅម៉ានីឡា........២០
-កិច្ចប្រជុំចំនួនពីរ នៅលេខាធិការដ្ឋានអាស៊ាន....................២២
-សកម្មភាពអន្តរជាតិសំខាន់ៗរបស់ថ្នាក់ដឹកនាំក្រសួង.........២៤
-ពិធីចុះអនុស្សរណៈយោគយល់គ្នាលើគម្រោង...................២៦
-វគ្គបណ្ដុះបណ្ដាលស្ដីពីការរៀបចំផែនការថវិកា.................២៨
-វេទិកា ស្ដីពីបញ្ហាប្រឈមរបស់យុវវ័យនៅក្នុងសង្គម...........៣២
- វេទិកា យុវជនរួមគ្នាទប់ស្កាត់អំពើហិង្សាលើស្ត្រី....................៣៤
-ពីមន្ត្រីសាលាខេត្តឈានដល់អភិបាលក្រុងច្បារមន ...........៣៥
-ស្ត្រីដែលជាប់ជាប្រធានសង្កាត់រហូតតាំងពី.......................៣៦
-ស្ត្រី និងសិប្បកម្មហូល....................................................៣៨
-ស្ត្រីគំរូក្នុងវិស័យកសិកម្ម..................................................៣៩



**ការិយាល័យនិពន្ធ**
**នាយកដ្ឋានព័ត៌មាន ក្រសួងកិច្ចការនារី ផ្លូវត្រុងមាន់ ភូមិដំណាក់ធំIII សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ**
Editorial Office : Information Department, Ministry of Women's Affairs
Street Trung Meann,Phum DamNakThom III, S.K. Steng MeanChey, Khan MeanChey, Phnom Penh, Cambodia. Tel: 023 880 737

# កិច្ចប្រជុំកំពូលអង្គការសហប្រជាជាតិ




សម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងកិច្ចប្រជុំកំពូលអង្គការសហប្រជាជាតិ

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអង្គការសហប្រជាជាតិ(អ.ស.ប.) ដែលបានប្រារព្ធឡើងចាប់ពីថ្ងៃទី២៥-២៧ ខែកញ្ញា ឆ្នាំ២០១៥ នៅទីក្រុងញូយ៉ក។ មេដឹកនាំពិភពលោកចំនួន ១៩៣ ប្រទេស បានអនុម័តរបៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ ដែលមានឈ្មោះថា " **គោលដៅអភិវឌ្ឍន៍ប្រកប ដោយចីរភាព (Sustainable Developments Goals-SDGs)** " ដែលមាន ១៧ គោលដៅ (17 goals) និង ១៦៩ ចំណុចដៅ (169 targets)។ គោលដៅ និងចំណុចដៅទាំងនេះ នឹងបំផុសឲ្យមានសកម្មភាពជាក់ស្តែង សម្រាប់រយៈពេល ១៥ ឆ្នាំ ខាងមុខទៀត គិតចាប់ពីដាច់ឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០៣០។

**គោលដៅទី១៖** បំបាត់ភាពក្រីក្រនៅទូទាំងពិភពលោក ទោះជាក្នុងទម្រង់ណាមួយនៃភាពក្រីក្រក៏ដោយ។

**គោលដៅទី២៖** លុបបំបាត់ស្ថានភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង និង អាហារូបត្ថម្ភដែលមានគុណភាពកាន់តែប្រសើរ និងលើកកម្ពស់ផលិតភាពកសិកម្មប្រកបដោយចីរភាព។

**គោលដៅទី៣៖** ធានាឱ្យប្រជាជនមានសុខភាពល្អនៅក្នុងជីវភាពរស់នៅ និងលើកកម្ពស់សុខុមាលភាពសម្រាប់ទាំងអស់គ្នា និងសម្រាប់ប្រជាជនគ្រប់វ័យ។

**គោលដៅទី៤៖** ធានាឱ្យបាននូវការអប់រំបរិយាប័ន្ន ដែលមានគុណភាពនិងដោយ ស្មើភាព និងធានាឱ្យមានការបង្កើនឱកាសរៀនអស់មួយជីវិតសម្រាប់ទាំងអស់គ្នា ។

**គោលដៅទី៥៖** សម្រេចឱ្យបានសមភាពយេនឌ័រ និងមានការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងនារីគ្រប់រូប។

**គោលដៅទី៦៖** ធានាឱ្យបាននូវការគ្រប់គ្រងទឹក និងការថែរក្សាអនាម័យសម្រាប់ទាំងអស់គ្នាប្រកបដោយចីរភាព។

**គោលដៅទី៧៖** ធានាឱ្យមានលទ្ធភាពអាចប្រើប្រាស់ថាមពលសម័យថ្មីដែលអាចជាទីទុកចិត្ត និង ប្រកប ដោយចីរភាពសម្រាប់ទាំងអស់គ្នា។

**គោលដៅទី៨៖** ជំរុញឱ្យមានកំណើនសេដ្ឋកិច្ចដែលផ្តល់ឱកាសស្មើភាពគ្នា និងដែលប្រកបដោយ ចីរភាព តាមរយៈការបង្កើតឱ្យមានការងារធ្វើពេញម៉ោង និង ការងារដែលអាចទទួល ផលខ្ពស់ និងដែលមានលក្ខខណ្ឌសមរម្យសម្រាប់ទាំងអស់គ្នា។

**គោលដៅទី៩៖** កសាងហេដ្ឋារចនាសម្ព័ន្ធដែលមិនឆាប់ទ្រុឌទ្រោម, លើកកម្ពស់ឧស្សាហាភាវូបនីយកម្ម ប្រកបដោយចីរភាព និងគ្រប់ជ្រុងជ្រោយ និងលើកទឹកចិត្តឱ្យមានគំនិតច្នៃប្រឌិតថ្មី។

**គោលដៅទី១០៖** កាត់បន្ថយកម្រិតវិសមភាពនៅក្នុងក្របខណ្ឌនៃប្រទេសនីមួយៗ និងនៅក្នុងចំណោម ប្រទេសទាំងអស់។

**គោលដៅទី១១៖** ធ្វើឱ្យទីក្រុង និងការតាំងទីលំនៅរបស់ប្រជាជន មានសុវត្ថិភាពគ្រប់ជ្រុងជ្រោយប្រកប ដោយចីរភាព និងដោយការមិនមើលរំលងទិដ្ឋភាពអវិជ្ជមាន។

**គោលដៅទី១២៖** ធានាឱ្យបានថា ពិតជាមាន គំរូ ឬស្តង់ដារ សម្រាប់ការប្រើប្រាស់ទំនិញ និងបែបផែន នៃផលិតកម្ម។

**គោលដៅទី១៣៖** ចាត់ឱ្យមានសកម្មភាពជាបន្ទាន់ដើម្បីទប់ទល់នឹងបាតុភូតនៃបម្រែបម្រួលធាតុអាកាស និងរាល់ផលប៉ះពាល់ដោយសារបាតុភូតធម្មជាតិនេះ។

**គោលដៅទី១៤៖** អភិរក្ស និងប្រើប្រាស់ មហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍនៅ ក្នុងលក្ខខណ្ឌដែលធានាឱ្យមានចីរភាព។

**គោលដៅទី១៥៖** ការពារ ស្តារ និង លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធអេកូស៊ីស្តែមនៅក្នុងលក្ខខណ្ឌដែល ធានាឱ្យមានចីរភាព, គ្រប់គ្រងព្រៃឈើនៅក្នុងលក្ខខណ្ឌដែលធានាឱ្យមានចីរភាព និង មានវិធានការទប់ស្កាត់រាល់ទង្វើប្រែក្លាយតំបន់ព្រៃឈើនិងដីធ្លីឱ្យទៅជាវាលខ្សាច់ដោយ តម្រូវឱ្យផ្អាករាល់សកម្មភាពដែលធ្វើឱ្យដីបាត់បង់គុណភាព និងផ្អាករាល់សកម្មភាព ដែលបំផ្លាញជីវចម្រុះ។

**គោលដៅទី១៦៖** ជំរុញ និងគាំពារឱ្យសង្គម មានសន្តិភាព/សុវត្ថិភាព និងមានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋ-កិច្ច ដែលត្រូវបានកែលំអដើម្បីគាំពារឱ្យការអភិវឌ្ឍ ប្រកបដោយចីរភាព, មានលទ្ធភាព ផ្តល់យុត្តិធម៌សម្រាប់ទាំងអស់គ្នា និងបង្កើតស្ថាប័ន ដែលបំពេញមុខងាររៀងៗខ្លួនបាន ល្អនៅគ្រប់លំដាប់ថ្នាក់។

**គោលដៅទី១៧៖** ពង្រឹងមធ្យោបាយនៃការអនុវត្តភាពជាដៃគូជាសកល និងជំរុញឱ្យមានសកម្មភាពរស់ រវើកឡើងវិញនូវភាពជាដៃគូសកលដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព៕

# ចំណុចសំខាន់ៗ
# សម្រាប់ការចូលរួមមតិរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# នៅក្នុងកិច្ចប្រជុំប្រមុខដឹកនាំពិភពលោក ស្តីពីសមភាពយេនឌ័រ
# និងការលើកកម្ពស់សិទ្ធអំណាចស្ត្រី
# ទីក្រុងញូយ៉ក, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៥

***ឯកឧត្តមប្រធាន,***

***ឯកឧត្តម, លោកជំទាវ, អស់លោក, លោកស្រី!***

ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយបានចូលរួមនៅក្នុង " **កិច្ចប្រជុំប្រមុខដឹកនាំពិភពលោក ស្តីពី សមភាពយេនឌ័រ និងការលើកកម្ពស់សិទ្ធអំណាចស្ត្រី: ការប្តេជ្ញាចិត្តឆ្ពោះទៅរកវិធានការ**"។ កាលពីម្ភៃឆ្នាំមុន យើងបានជួបជុំគ្នាដូចនេះដែរ នៅទីក្រុងប៉េកាំង ក្នុង"**សន្និសិទពិភពលោកលើកទីមួយស្តីពីស្ត្រី**"នាឆ្នាំ១៩៩៥ដោយបានអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំងនិងផែនការសកម្មភាព។ ចាប់តាំងពីពេលនោះមក ផែនការសកម្មភាពទីក្រុងប៉េកាំងបានក្លាយជាឧបករណ៍ដ៏សំខាន់សម្រាប់ការលើកកម្ពស់សមភាពយេនឌ័រទាំងក្នុងទិដ្ឋភាពសេដ្ឋកិច្ច និងសង្គម។

នៅក្នុងក្របខ័ណ្ឌនេះ កម្ពុជាបានចូលរួមយ៉ាងសកម្មជាមួយបណ្តាប្រទេសសមាជិកនៃ អង្គការសហប្រជាជាតិ ក្នុងការអនុវត្តគោលនយោបាយ, យុទ្ធសាស្ត្រ, កម្មវិធី និងផែនការសកម្មភាពនានា សំដៅលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រី ហើយសម្រេចបាននូវវឌ្ឍនភាពជាច្រើនតាមវិស័យសំខាន់ៗ រួមមាន៖

- ការអនុម័តច្បាប់ និងក្របខ័ណ្ឌនិយ័តកម្ម ដើម្បីផ្តល់ការគាំពារ, លុបបំបាត់ការរើសអើង និងកាត់បន្ថយអំពើហិង្សាលើស្ត្រី និងក្មេងស្រី,
- ការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យអប់រំ តាមរយៈការបង្កើនការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា,
- ការលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច និងការបង្កើនភាពងាយស្រួលដល់ស្ត្រីក្នុងការទទួលបានសេវាហិរញ្ញវត្ថុ សំដៅបង្កើនភាពឯករាជ្យផ្នែកហិរញ្ញវត្ថុរបស់ស្ត្រី,
-ការលើកកម្ពស់ស្ថានភាពសុខភាពរបស់ស្ត្រី និងកុមារ ពិសេសតាមរយៈការសម្រេចបាន នូវគោលដៅ

អភិវឌ្ឍន៍សហសហស្សវត្សរ៍លើមរណភាពមាតា, និង

- ការលើកកម្ពស់ការចូលរួមរបស់ស្ត្រី នៅក្នុងកិច្ចការនយោបាយ និងការសម្រេចចិត្តលើកិច្ចការនានារបស់សង្គមជាតិ ក្នុងគ្រប់ស្ថាប័នជាតិ និងគ្រប់កម្រិត ជាអាទ៍ស្ថាប័ននីតិបញ្ញត្តិ, ស្ថាប័ននៃរាជរដ្ឋាភិបាល និងស្ថាប័នផ្សេងៗ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ឆ្នាំ ២០១៥ នេះ គឺជាឆ្នាំប្រវត្តិសាស្ត្រមួយសម្រាប់ពន្លឿនវឌ្ឍនភាពឆ្ពោះទៅរកសមភាព យេនឌ័រ និងការលើកកម្ពស់សិទ្ធអំណាចស្ត្រី ។ ជាការពិតកិច្ចប្រជុំនេះ នឹងក្លាយជាវេទិកាដ៏សំខាន់សម្រាប់យើងទាំងអស់គ្នាក្នុងការបន្តខិតខំប្រឹងប្រែង និងប្តេជ្ញាចិត្តបន្ថែមទៀត ដើម្បីសម្រេចនូវសមភាពយេនឌ័រ និងធ្វើឱ្យគោលដៅនេះ ក្លាយជាការពិតសម្រាប់ស្ត្រី និងក្មេងស្រីទាំងអស់ទូទាំងពិភពលោក។ ជាមួយហេតុផលនេះ ខ្ញុំយល់ថាយើងគួរបន្តផ្តោតអាទិភាពទៅលើការងារមួយចំនួន ដូចខាងក្រោម៖

***១- ការបង្កើនការវិនិយោគលើសមភាពយេនឌ័រ***

*ពិសេសតាមរយៈពិនិត្យឡើងវិញលើគោលនយោបាយសារពើពន្ធ ដើម្បីបង្កើត និងបង្កើនចំណាយសាធារណៈទៅលើសមភាពយេនឌ័រ ព្រមទាំងត្រួតពិនិត្យ និងវិភាគផលប៉ះពាល់នៃចំណាយសាធារណៈទៅលើវិសមភាពយេនឌ័រ តាមរយៈការធ្វើកម្មវិធីថវិកា ដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ។*

***២- ការធានានូវការការពារសិទ្ធរបស់ស្ត្រី ព្រមទាំងការចូលរួមពេញលេញ និងស្មើភាពរបស់ ស្ត្រី នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិត។***

***៣- ការពង្រឹងយន្តការគណនេយ្យភាពសម្រាប់សមភាពយេនឌ័រ***

*តាមរយៈការពង្រឹងស្ថាប័នរដ្ឋាភិបាល ព្រមទាំងការប្រើប្រាស់មធ្យោបាយនៃការតាមដានត្រួតពិនិត្យវឌ្ឍនភាពទាំងឡាយប្រកបដោយប្រសិទ្ធភាព និងការធានាផ្តល់ធនធានឱ្យបានគ្រប់គ្រាន់សម្រាប់ការងារយេនឌ័រ។*

***៤- ការបន្តលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងសេដ្ឋកិច្ច និងបរិយាប័ន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី*** *ពិសេសតាមរយៈការបង្កើនការយល់ដឹងអំពីសេវាអភិវឌ្ឍអាជីវកម្មសំខាន់ៗ សម្រាប់សហគ្រាសស្ត្រីខ្នាតមីក្រូ, ខ្នាតតូច និងមធ្យម, ការបង្កើតនូវកម្មវិធីនានា ដើម្បីជួយឱ្យស្ត្រីទទួលបាននូវជំនាញ បច្ចេកទេស, សហគ្រិនភាព និង សេវាហិរញ្ញវត្ថុ, គាំទ្រស្ត្រីក្នុងការធ្វើពិពិធកម្ម និងពាណិជ្ជូបនីយកម្មលើវិស័យកសិកម្ម ព្រមទាំងកិច្ចសហការជាមួយភាគីពាក់ព័ន្ធនានានៅក្នុងទីផ្សារ ការងារ ដើម្បីលុបបំបាត់ការរើសអើងស្ត្រីនៅកន្លែងការងារ, រៀបចំស្តង់ដារពលកម្មសម្រាប់ស្ត្រី, ផ្តល់ការគាំពារសង្គម និងជួយដោះស្រាយវិវាទជាដើម។ល។៕*

សូមអរគុណ!

# កម្មវិធីផ្សព្វផ្សាយជាផ្លូវការផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០១៥-២០១៨ ក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម



គណៈអធិបតីថតរូបអនុស្សាវរីយ៍ជាមួយអ្នកចូលរួម

កាលពីថ្ងៃទី០៩ខែកក្កដាឆ្នាំ២០១៥លោកជំទាវវេជ្ជបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារីបានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងសិក្ខាសាលាផ្សព្វផ្សាយឱ្យប្រើប្រាស់ជាផ្លូវការផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រឆ្នាំ២០១៥-២០១៨ ក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្មដែលរៀបចំដោយក្រសួងឧស្សាហកម្មនិងសិប្បកម្មសហការជាមួយក្រសួងកិច្ចការនារីនិងគាំទ្រដោយអង្គការ JICA នៅសណ្ឋាគារសាន់វ៉េ នាទីក្រុងភ្នំពេញ ដែលមានអ្នកចូលរួមសរុបប្រមាណ១០០នាក់។ សិក្ខាសាលានេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តម **ចម ប្រសិទ្ធិ** ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ក្នុងសុន្ទរកថាបើកសិក្ខាសាលា ឯឧត្តម **ចម ប្រសិទ្ធិ** ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្មបានមានប្រសាសន៍ថា គិតពីចំនួនគឺសហគ្រាសខ្នាតមីក្រូមានជាង៥០០,០០០ ហើយដែលភាគច្រើនគឺដឹកនាំដោយស្ត្រី។ ឯកឧត្តមបានចាត់ទុកថាការងារបញ្ជ្រាបយេនឌ័រ គឺមានសារៈសំខាន់ណាស់ ហើយបញ្ហាដែលធ្វើឱ្យមានគម្លាតយេនឌ័រ គឺបណ្តាលមកពីតំណៃនៃសង្គមវប្បធម៌ជាច្រើនជំនាន់របស់ខ្មែរ ដែលមិនឱ្យកូន

ស្រីរៀន ហើយស្ត្រីមិនសូវមានតំណែងជាអ្នកដឹកនាំ ហើយមានតែអគ្គមហេសីរបស់ព្រះបាទជ័យវរ្ម័នទី៧ គឺព្រះនាងឥន្ទ្រទេវីដែលបានបង្រៀនឱ្យស្ត្រីចេះអានអក្សរ ។ ចំណែកឯប្រុសៗ គឺនៅវត្ត តែស្ត្រីមិនអាចរៀននៅវត្តបាន ដូច្នេះហើយកូនៗនៅជនបទមិនចេះអក្សរ ។ ក្នុងសម័យដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុនសែន** គឺបានយកចិត្តទុកដាក់ខ្លាំងលើវិស័យអប់រំ ដោយបានបង្កើតសាលារៀនរហូតដល់ថ្នាក់ឃុំ និងការសាងសង់អន្តេវាសិកដ្ឋានសម្រាប់សិស្សស្រីដើម្បីបន្តការសិក្សាបានកម្រិតខ្ពស់។ ឯកឧត្តមបានបញ្ជាក់ថា ដើម្បីពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី គឺត្រូវពង្រឹងសមត្ថភាពរបស់ស្ត្រី និងផ្តល់ការបណ្តុះបណ្តាលស្ត្រីបានច្រើន ។ ឯកឧត្តមបានកត់សម្គាល់ឃើញថាការគ្រប់គ្រងសហគ្រិនដោយនារីគឺមានប្រសិទ្ធភាពជាងបុរស ព្រោះស្ត្រីធ្វើការហ្មត់ចត់ និងយកចិត្តទុកដាក់ជាងបុរស ។ ឯកឧត្តមបានវាយតម្លៃថាក្រុមការងារយេនឌ័ររបស់ក្រសួងឧស្សហកម្ម និងសិប្បកម្ម គឺសកម្ម ប៉ុន្តែឯកឧត្តមក៏បញ្ជាក់ផងដែរថាការផ្តល់តួនាទីជូនស្ត្រីមិនមែនចេះតែឱ្យតាមកូតានោះទេ គឺត្រូវផ្អែកលើសមត្ថភាពផងដែរដើម្បីឱ្យស្ត្រីដែលជាអ្នកដឹកនាំមានតម្លៃ។ បញ្ហាលំបាក គឺមិនសូវមាននារីរៀនបច្ចេកវិទ្យា ដូចជា វិស្វករ គឺមីម្ហូបអាហារ និងវិស្វករសំណង់ ដូច្នេះក្រសួងពិបាកក្នុងការជ្រើសរើសស្ត្រីឱ្យចូលបម្រើការងារជាមន្ត្រីរាជការនៅតាមមន្ទីរឧស្សាហកម្ម និងសិប្បកម្មគ្រប់រាជធានីខេត្ត។

លោកជំទាវវេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារីបានមានប្រសាសន៍ពន្យល់អំពីសារៈសំខាន់នៃការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី គឺសំដៅបង្កើនសមត្ថភាពរបស់ស្ត្រីលើផ្នែកសេដ្ឋកិច្ច ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជា និងអំពើហិង្សាក្នុងគ្រួសារផងដែរ។ ក្រសួងកិច្ចការនារីបានកំណត់អាទិភាពសំខាន់ៗចំនួនប្រាំក្នុង " **ផែនការនារីរតនៈទី៤** " របស់ខ្លួនគឺ៖ ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ការផ្សព្វផ្សាយអប់រំស្ត្រីឱ្យមានការយល់ដឹងអំពីបញ្ហាសុខភាពនិងចេះថែទាំសុខភាព រួមទាំងសុខភាពផ្លូវភេទ កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី ការលើកកម្ពស់ ការចូលរួមរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច ក្នុងវិស័យសាធារណៈ និងនយោបាយ និងការធ្វើយ៉ាងណាឱ្យស្ត្រីមានភាពឯករាជ្យផ្នែកសេដ្ឋកិច្ច៕

# សិក្ខាសាលាបញ្ចប់គម្រោងបញ្ជ្រាបយេនឌ័រដំណាក់កាលទី២



លោកជំទាវវេជ្ជ. អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារីទទួលបាច់ផ្កាពីលោក KOJICA TAKEHARU តំណាងជាន់ខ្ពស់របស់អង្គការ JICA

ក្រសួងកិច្ចការនារី បានរៀបចំសិក្ខាសាលាបញ្ចប់គម្រោងបញ្ជ្រាបយេនឌ័រដំណាក់កាលទី២ បន្ទាប់ពីការអនុវត្តរយៈពេល៥ឆ្នាំ (២០១០-២០១៥) នៅខេត្តកំពង់ចាម ដែលមានអ្នកចូលរួមចំនួន ៣៥០នាក់ (ស្ត្រី២០០នាក់) មកពីក្រសួង/មន្ទីរកិច្ច-ការនារីទាំង២៥ខេត្ត/រាជធានី និងសមាជិកក្រុមការ-ងារបញ្ជ្រាបយេនឌ័រនៃក្រសួង/មន្ទីរ ដៃគូពាក់ព័ន្ធទាំង៦រួមមាន៖ ឧស្សាហកម្មនិងសិប្បកម្ម ផែនការ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អភិវឌ្ឍន៍ជនបទ ពាណិជ្ជកម្ម និងក្រសួងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាពលោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី នៅសណ្ឋាគារភ្នំពេញ កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ ។



ថ្នាក់ដឹកនាំចូលរួមក្នុងអង្គសិក្ខាសាលា

គម្រោងសាកល្បងរបស់PGM2 បានផ្តល់ដល់ក្រុមគោលដៅ នូវវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ វគ្គផ្នែកអាជីវកម្ម និងព័ត៌មានទីផ្សារផងដែរ៕

# កម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍ !





លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារីបានផ្តល់អនុសាសន៍ដល់ប្រតិភូយុវជនកម្ពុជា

កាលពីថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៥លោកជំទាវ វេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រី ក្រសួងកិច្ចការនារីបាន អនុញ្ញាតឱ្យប្រតិភូយុវជនកម្ពុជានៃកម្មវិធីនាវា យុវជនអាស៊ីអាគ្នេយ៍ចំនួន២៩នាក់ (ស្ត្រី១២នាក់) ចូលជួបសម្តែងការគួរសម ។ ក្នុងជំនួបនេះលោក-ជំទាវរដ្ឋមន្ត្រីបានផ្តល់ជាអនុសាសន៍មួយចំនួនដូច ជាផ្តល់តម្លៃនៃការចែករំលែកការងារផ្ទះរវាងបុរស និងស្ត្រី បញ្ហាគ្រឿងញៀន និងការប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គមក្នុងន័យវិជ្ជមាន ។

ប្រតិភូយុវជននេះនឹងគ្រោងធ្វើដំណើរទៅ បំពេញបេសកកម្មនៅប្រទេសជប៉ុន និងបណ្តា ប្រទេសអាស៊ីមួយចំនួន ក្នុងគោលបំណងផ្សព្វ-ផ្សាយអំពីសិល្បៈ វប្បធម៌ និងអរិយធម៌ដ៏រុងរឿង របស់ប្រទេសកម្ពុជាដែលធ្លាប់តែល្បីល្បាញជាយូរ លង់ណាស់មកហើយ ៕



ថ្នាក់ដឹកនាំក្រសួងកិច្ចការនារីថតរូបអនុស្សាវរីយ៍ជាមួយប្រតិភូយុវជនកម្ពុជា




សិក្ខាសាលាផ្សព្វផ្សាយការអនុវត្តគម្រោងយេនឌ័រ ឆ្លើយតបការប្រែប្រួលអាកាសធាតុជាសកល បានប្រព្រឹត្តទៅនៅសណ្ឋាគារភ្នំពេញ កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវវេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ដោយមានការចូលរួមរបស់តំណាងក្រសួង-មន្ទីរពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលសរុបចំនួន១៨០នាក់ ក្រោមការជួយឧបត្ថម្ភរបស់អង្គការ UNDP។ គោលបំណងសិក្ខាសាលា ដើម្បីចែករំលែកនូវព័ត៌មានជាគន្លឹះមួយចំនួនជាមួយនឹងអ្នកពាក់ពន្ធ័អំពីការអនុវត្តគម្រោងយេនឌ័រឆ្លើយតបការបម្រែបម្រួលអាកាសធាតុជាសកល និងផលប៉ះពាល់នៃការបម្រែបម្រួលអាកាសធាតុទៅលើស្ត្រី និងកុមារ។



កាលពីថ្ងៃទី២១ដល់ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ នៅសណ្ឋាគារភ្នំពេញ ក្រសួងកិច្ចការនារីសហការជាមួយអង្គការ UNICEF បានរៀបចំកិច្ចប្រជុំលើកទី១ ជាមួយគណៈកម្មការដឹកនាំក្រុមការងារបច្ចេកទេស ដើម្បីរៀបចំផែនការសកម្មភាព ស្តីពី ការទប់ស្កាត់អំពើហិង្សាលើកុមារ ។ កិច្ចប្រជុំបានពិភាក្សាលើរចនាសម្ពន្ធ័ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសទាំង៤ក្រុមមាន៖ ១-ក្រុមការងារបង្ការ ២-ក្រុមការងារឆ្លើយតប ៣-ក្រុមការងារ ស្តីពីច្បាប់ និងគោលនយោបាយ ៤-ក្រុមការងារ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ដែលមានអ្នកចូលរួមទាំង៤ក្រុមសរុបចំនួន១១២នាក់ (ស្ត្រី៦៧នាក់)។

# សិក្ខាសាលាស្តីពី ការអភិវឌ្ឍសមាគមអាជីវកម្មស្ត្រី




លោកជំទាវរដ្ឋមន្ត្រីថតរូបអនុស្សាវរីយ៍ជាមួយសិក្ខាកាម

នាយកដ្ឋានអភិវឌ្ឍសេដ្ឋកិច្ច នៃក្រសួងកិច្ចការនារី បានសហការជាមួយអង្គការ UNDP រៀបចំសិក្ខាសាលា ក្រោមអធិបតីភាពលោកជំទាវ វេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ស្តីពី ការអភិវឌ្ឍសមាគមអាជីវកម្មស្ត្រី នៅខេត្តព្រះសីហនុ ថ្ងៃទី២១-២២ ខែកញ្ញា ឆ្នាំ២០១៥ គោលបំណងនៃសិក្ខាសាលាគឺ ១. បង្កើតជាវេទិកាដល់សមាគមអាជីវកម្ម ក្នុងការចែករំលែក និងផ្លាស់ប្តូរបទពិសោធន៍ ស្តីពីការគ្រប់គ្រងសមាគមអាជីវកម្ម ការដោះស្រាយបញ្ហាប្រឈមនៅក្នុងសមាគម ការផ្តល់សេវា ការកៀងគរសមាជិក និងផែនការអភិវឌ្ឍសមាគម

vfd២.បង្កើនចំណេះដឹងលើការគ្រប់គ្រងសមាគម ការចុះបញ្ជីសមាគមអាជីវកម្ម នាំចេញនាំចូល

៣.បង្កើតទំនាក់ទំនងរវាងសមាគមអាជីវកម្ម។



លោកជំទាវរដ្ឋមន្ត្រីពិនិត្យសមិទ្ធិផលរបស់សមាគម អាជីវកម្មស្ត្រី នៅខេត្តព្រះសីហនុ

# សិក្ខាសាលាស្តីពី " យេនឌ័រ និងគោលនយោបាយសេដ្ឋកិច្ច "




គណៈអធិបតីក្នុងអង្គសិក្ខាសាលា

កាលពីថ្ងៃទី ០៦ដល់ថ្ងៃទី០៨ ខែតុលា ឆ្នាំ ២០១៥ នៅសណ្ឋាគារសោមាទេវី ខេត្តសៀមរាប មានរៀបចំសិក្ខាសាលាមួយក្រោមប្រធានបទស្តីពី " **យេនឌ័រ និងគោលនយោបាយសេដ្ឋកិច្ច** " ក្រោមអធិបតីភាពរបស់លោកជំទាវ **ឃឹម ចំរើន** រដ្ឋលេខាធិការក្រសួងកិច្ចការនារី ដោយមានការចូលរួមពីក្រុមបច្ចេកទេសយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជនសរុបចំនួន ៦២នាក់ (ស្ត្រី ៥៧)។ អង្គសិក្ខាសាលាបានស្តាប់នូវបទបង្ហាញស្តីពី៖

១-ទិដ្ឋភាពទូទៅពីយេនឌ័រ និងទស្សនទានសេដ្ឋកិច្ច
២-ហេតុអ្វីបានជាត្រូវពិចារណាពីយេនឌ័រនៅក្នុងសេដ្ឋកិច្ច, ៣- យេនឌ័រ និងភាពក្រីក្រ
៤-សកលភាវូបនីយកម្មដោយផ្តោតលើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងផលប៉ះពាល់លើយេនឌ័រ
៥-ពាណិជ្ជកម្មក្នុងតំបន់ និងការអភិវឌ្ឍសហគ្រាសរបស់ស្ត្រី , ៦-ចំណាកស្រុកក្រៅប្រទេស
៧-យេនឌ័រ សេដ្ឋកិច្ច និងបរិស្ថាន
៨-យេនឌ័រ និងហិរញ្ញវត្ថុ, ៩-ការរៀបចំផែនការថវិកាដែលឆ្លើយតបនឹងយេនឌ័រ
១០- វិធីសាស្ត្រធ្វើការសិក្សាស្រាវជ្រាវ ការតាមដាន និងវាយតម្លៃ ដោយគិតគូរពីយេនឌ័រ

នាឱកាសនោះ លោកជំទាវ **ឃឹម ចំរើន** រដ្ឋលេខាធិការក្រសួងកិច្ចការនារីបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលបាននឹងកំពុងបន្តការបញ្ជ្រាបយេនឌ័រក្នុងវិស័យសេដ្ឋកិច្ច ដោយបានចាត់ទុកស្ត្រីជាឆ្អឹងខ្នង នៃសេដ្ឋកិច្ច និងសង្គម៕



# យុវនារីនិទ្ទេស A

ក្នុងចំណោមបេក្ខជនប្រឡងមធ្យមសិក្សាទុតិយភូមិថ្ងៃទី២៤-២៥ ខែសីហា ឆ្នាំ២០១៥ ចំនួន ៨៣ ៣២៥នាក់ មានអ្នកប្រឡងជាប់ចំនួន ៤៦៥៦០នាក់( ៥៥.៨៨% ) ក្នុងនោះនិទ្ទេស A មាន១០៨នាក់ (យុវនារី ៤៩ នាក់)។

## រាជធានីភ្នំពេញ



**ម៉ក់ សោភ័ណ្ឌ**

កើត: ១៥/១០/១៩៩៧

វិទ្យាល័យច្បារអំពៅ

ឪពុក: ម៉ក់ រិន ជានគរបាល

ម្ដាយ:សួង លាភ ជាមេផ្ទះ



**វណ្ណា ភ័ណសុធា**

កើត: ១៤/០៣/១៩៩៨

វិទ្យាល័យបែលធីអន្តរជាតិទី៩

ឪពុក: ស្រី សោភ័ណ

ជាបុគ្គលិកក្រុមហ៊ុន

-ម្ដាយ: សុខ ច័ន្ទធី ជាមេផ្ទះ



**ជិន ច័ន្ទដាលុច្ស**

កើត:១៧ /០៥/១៩៩៧

វិទ្យាល័យអន្តរទ្វីប

អាមេរិកាំង

ឪពុក: ជិន ដា

ជាមន្ត្រីជលផល

ម្ដាយ: អ៊ូ ស ជាមេផ្ទះ



**ប្រាក់ សុគះ**

កើត: ០៨ /១០/១៩៩៦

វិទ្យាល័យ ហាសបន វត្តភ្នំ

ឪពុក: ប្រាក់ សម្បត្តិ

ជាមន្ត្រីរាជការ

ម្ដាយ: ឡៅ វណ្ណី ជាមេផ្ទះ



**អ៊ុខ ម៉ារឌី**

កើត:១៣ /០៧/១៩៩៧

វិទ្យាល័យបាក់ទូក

ឪពុក: អ៊ុង មីនា

ជាមន្ត្រីរាជការ

ម្ដាយ:នៅ ច័ន្ទនី ជាមេផ្ទះ



**ជា ម៉ាលីណែត**

កើត:០៨/០៩/១៩៩៧

វិទ្យាល័យ បាក់ទូក

ឪពុក: សូ ម៉េងចាន់

ជា មន្ត្រីរាជការ

ម្ដាយ: ប៊ុន្នី គន្ធា ជាមេផ្ទះ

# យុវនារីនិទ្ទេស A



**សេង មួយឡេង**

កើត:១៣/១២/១៩៩៧

វិទ្យាល័យ

បែលធីអន្តរជាតិទី៣

ឪពុក: សេង ស៊ីណា

ជា មន្ត្រីសុខាភិបាល

ម្តាយ:ហ៊ឹម លក្ខិណា ជាមេផ្ទះ



**រ័ត្ន ច័ន្ទស្មី**

កើត:០៥/១០/១៩៩៨

វិទ្យាល័យ ឥន្ទ្រទេវី

ឪពុក: រ័ត្ន ថាវរោ

ជាមន្ត្រីរាជការ

ម្តាយ: រ៉ាកន កល្យាណ (ស្លាប់)



**លឹម ស៊ូឈី**

កើត: ១៩/០៨/១៩៩៨

វិទ្យាល័យ បែលធីអន្តរជាតិ

ទី១១

ឪពុក:លឹម ចេង ជា កងទ័ព

ម្តាយ: ញែម សោភ័ណ្ឌ

ជាអាជីវករ



**អ៊ុក ករុណា**

កើត:០៥/១១/១៩៩៦

វិទ្យាល័យ បាក់ទូក

ឪពុក:អ៊ុក គឹមផូរ ជាជាងចម្លាក់

ម្តាយ: អោក ម៉ាឡា ជាមេផ្ទះ



**សុង លួហ្ស៊ី**

កើត: ២១/០៨/១៩៩៧

វិទ្យាល័យ

អន្តរទ្វីបអាមេរិកាំង

ឪពុក: សុង វ៉េង ជាអាជីវករ

ម្តាយ: យី សុភក្ត្រ័ ជាអាជីវករ



**អ៊ឹង អេឌី**

កើត: ០៤ /០១/១៩៩៩

វិទ្យាល័យ ព្រះស៊ីសុវត្ថិ

ឪពុក: អ៊ឹង ង៉ោហុក

ជា ប្រធាននាយកដ្ឋាន

ម្តាយ: មឹង ម៉ាលីវណ្ណ

ជាគ្រូបង្រៀន



**ល័ក្ខ សុផាវត្តី**

កើត:២៩/១១/១៩៩៨

វិទ្យាល័យ អន្តរទ្វីបអាមេរិកាំង

ឪពុក: សាង ល័ក្ខ

ជាមន្ត្រីរាជការ

ម្តាយ:អ៊ួច សុផាវី

ជាមន្ត្រីរាជការ



**សេង ហ្គិចលី**

កើត:០៧/១១/១៩៩៧

វិទ្យាល័យ

បែលធីអន្តរជាតិទី៦

ឪពុក: សេង សាន ជាអាជីវករ

ម្តាយ: ម៉ី ស្រីមុំ ជាមេផ្ទះ

# យុវនារីនិទ្ទេស A



**សៀក បូរមី**

កើត:២០/០៨/១៩៩៨
វិទ្យាល័យ ហាស ភ្នំពេញថ្មី
ឪពុក: សៀក សេរីសោភា
ជាគ្រូពេទ្យ
ម្តាយ: ហាម សុខលន់
ជាមេផ្ទះ



**សុក ធីតា**

កើត: ០៦/០៣/១៩៩៧
វិទ្យាល័យ
បែលធីអន្តរជាតិទី៣
ឪពុក: សៀក ចំរើន
ជាគ្រូពេទ្យ
ម្តាយ: ទេព ភិរុន គ្មាន



**វណ្ណា តារាស្មី**

កើត: ០១/០៥/១៩៩៧
វិទ្យាល័យ ព្រះស៊ីសុវត្ថិ
ឪពុក: ជឹង វណ្ណា
ជាបុគ្គលិកក្រុមហ៊ុន
ម្តាយ: ទី សុភិន ជាមេផ្ទះ



**លី ដានីត**

កើត: ១១/១២/១៩៩៧
វិទ្យាល័យបាក់ទូក
ឪពុក: អ៊ាន ហុងលី
ជាមន្ត្រីរាជការ
ម្តាយ: អ៊ាប គឹមអ៊ែង ជាមេផ្ទះ



**ហេង លក្ស្មី**

កើត: ០៣/០២/១៩៩៨
វិទ្យាល័យ ព្រះយុគន្ធរ
ឪពុក: នង ប៊ុនហេង
ជានាយកសាលា
ម្តាយ: ជី ច័ន្ទនី ជាគ្រូបង្រៀន



**ទូច ច័ន្ទនិមល**

កើត: ០៩/០៣/១៩៩៧
វិទ្យាល័យអន្តរជាតិហ្សាម៉ាន់
ឪពុក: ទូច សុធន
ជាគ្រូបង្រៀន
ម្តាយ: សុខុម ចន្ទី
ជាគ្រូបង្រៀន



**ហាន សោភ័ណ្ឌទេវី**

កើត: ២២/០៧/១៩៩៨
វិទ្យាល័យ
បែលធីអន្តរជាតិទី១
ឪពុក: ហាន ម៉េងលី
ជាអាជីវករ
ម្តាយ: ផូវ សោភ័ណ្ឌ ជាមេផ្ទះ

## ខេត្តព្រះវិហារ



**សារៈ អាលីហ្សា**

កើត: ០៣/០៨/១៩៩៩
វិទ្យាល័យ:ជស ត្បែងមានន័យ
ឪពុក: ខៀវ សារៈ ជាអាជីវករ
ម្តាយ: ប៊ុន សិលា ជាអាជីវករ

# យុវនារីនិទ្ទេស A

## ខេត្តកណ្តាល



**លីម មួយគារ**

កើត: ២៣/០៣/១៩៩៧

វិទ្យាល័យជ័យវរ្ម័នទី៧

ឪពុក: យុន ច័ន្ទ្រតារា

ជាកសិករ

ម្តាយ: ជា សារឹម ជាកសិករ



**ឋាម សុធៀន**

កើត: ២៧/០២/១៩៩៧

វិទ្យាល័យ សហ សេរីភាព

ឪពុក: ជា ឋាម

ជាមន្រ្តីរាជការ

ម្តាយ: ទ្រី វណ្ណី ជាមេផ្ទះ

## ខេត្តកំពត



**យុន ស្រីកែវ**

កើត: ០៩/០៧/១៩៩៧

វិទ្យាល័យ ហាស ឈូក

ឪពុក: វៀច យាល ជាកសិករ

ម្តាយ:សែ ស្តើង ជាកសិករ



**សេង លីសែហុង**

កើត: ០៩/០៨/១៩៩៨

វិទ្យាល័យ បនហាស ដងទង់

ឪពុកឈ្មោះ សេង ឫទ្ធី

ជានគរបាល

ម្តាយ: នេត កែវ

ជាគ្រូបង្រៀន

## ខេត្តបន្ទាយមានជ័យ



**សួន កន្និកា**

កើត: ១៨/០១/១៩៩៨

វិទ្យាល័យ ឯកជនឧត្តមវិជ្ជា

ឪពុក: ស៊ីវ ស៊ឹប

ជានគរបាល

ម្តាយ: អ៊ុន សុភក្រ្តកញ្ញា

ជាគ្រូបង្រៀន



**ធៀង គេទីត**

កើត: ០២/០៨/១៩៩៨

វិទ្យាល័យ ហាស មង្គលបូរី

ឪពុក: សួន មាន

ជាគ្រូបង្រៀន

ម្តាយ: ហួត និមល ជាមេផ្ទះ

## ខេត្តតាកែវ



**អ៊ិន ចរិយា**

កើត: ១៨/០៧/១៩៩៦

វិទ្យាល័យសន្ទហ្វង់ស្វ័រ

ឪពុក: អ៊ិន ប៊ុនធឿន

ជាកសិករ

ម្តាយ: សែម ថារី ជាកសិករ



**ស្រី ច័ន្ទនាង**

កើត: ០៣/០៤/១៩៩៧

វិទ្យាល័យ ហាស ព្រៃល្វា

ឪពុក: មិន ចិត្ត ជាកសិករ

ម្តាយ: សេង សុភាព

ជាកសិករ

# យុវនារីនិទ្ទេស A

## ខេត្តត្បូងឃ្មុំ



**ស៊ឹម សុខឡែន**

កើត: ១២/០៥/១៩៩៨

វិទ្យាល័យ ហាស សួង

ឪពុក: ណុប ស៊ុនទី

ជាកសិករ

ម្តាយ: អ៊ូ ស៊ីណា ជាកសិករ



**សឿ ស៊ីថាន់**

កើត: ០៦/០៧/១៩៩៦

វិទ្យាល័យ ជស កណ្តោលជ្រុំ

ឪពុក: សឿ ស៊ីថា ជាកសិករ

ម្តាយ: ខាន់ ទូច ជាកសិករ



**ហ៊ត់ ស្រីណែត**

កើត: ១៣/០៦/១៩៩៧

វិទ្យាល័យ ពាមជាំង

ឪពុក: ថុង ឡុង ជាកសិករ

ម្តាយ: គង់ សុផល ជាមេផ្ទះ



**ហូល ឆៃលី**

កើត: ២៦/០១/១៩៩៧

វិទ្យាល័យ ក្រូចឆ្មារ

ឪពុក: ហូល កុយ ( ស្លាប់ )

ម្តាយ: តាំង ណៃហ៊ង

ជាកសិករ

## ខេត្តកំពង់ស្ពឺ



**ស៊ុំម ស្រីឡែន**

កើត: ០២/០៤/១៩៩៧

វិទ្យាល័យ ហាស ត្រពាំងឫស្សី

ឪពុក:ប៉ា ប៊ុនធឿន ជាកសិករ

ម្តាយ: វន់ ស្រី ជាកសិករ



**វ៉េន ម៉ុមមុនិតា**

កើត:៣០/១២/១៩៩៨

វិទ្យាល័យ ទ័ពមានជ័យ

ឪពុក: ជា សំណាង

ជាគ្រូបង្រៀន

ម្តាយ: ឡុង នាថ ជាគ្រូបង្រៀន

## ខេត្តកំពង់ធំ



**យុន ស្រីណុច**

កើត: ០៤/១០/១៩៩៨

វិទ្យាល័យ ហាស បល្ល័ង្គ

ឪពុក: ហួត គុយហេង

ជាកសិករ

ម្តាយ:ឌី គឹមហ៊ុន ជាមេផ្ទះ

## ខេត្តក្រចេះ



**នាង ពិសី**

កើត: ០២/០១/១៩៩៦

វិទ្យាល័យ:

ព្រះមហាក្សត្រីយានីកុសុមៈ

ឪពុក: មិន ណុំ ជាកសិករ

ម្តាយ: ភោគ សុធី ជាអាជីវករ

# យុវនារីនិទ្ទេស A

## ខេត្តសៀមរាប



**លី ហេងរីណា**

កើត:១៣/១២/១៩៩៧

វិទ្យាល័យ: ១០ មករា ១៩៧៩

ឪពុក: លី ឡៃហេង គ្រូបង្រៀន

ម្តាយ: ថាត សុគន្ធារី

ជាគ្រូបង្រៀន



**ចាន់ វណ្ណលីតា**

កើត: ២៣/០១/១៩៩៧

វិទ្យាល័យ អង្គរ

ឪពុក: ចាន់ ហេង ជាលក់ដូរ

ម្តាយ: គង់ អេន ជាមេផ្ទះ



**លាង រ៉ែតចរណៃ**

កើត: ០៩/១២/១៩៩៧

វិទ្យាល័យ:១០ មករា ១៩៧៩

-ឪពុក: លាង សារ៉េត

ជាអ្នកដឹកភ្ញៀវ

ម្តាយ: វង្ស រដ្ឋា

ជាបុគ្គលិកសណ្ឋាគារ



**រៀម សុខចំរើន**

កើត:១៦/០៣/១៩៩៦

វិទ្យាល័យ ពួក

ឪពុក: រិត រៀម ជាកសិករ

ម្តាយ: សែម ទូច ជាកសិករ



**ឈឿ ព្រីយ៉ាឡែន**

កើត: ២២/១១/១៩៩៧

វិទ្យាល័យ អង្គរ

ឪពុក: ឈឿ ប៊ុនលី

ជាគ្រូពេទ្យ

ម្តាយ: ដួង ថាវរី

ជានគរបាល



**សេង ឌីណាច់**

កើត: ០១/០២/១៩៩៧

វិទ្យាល័យ អង្គរ

ឪពុក: សេង សេរីវុធ

ជាលក់ដូរ

ម្តាយ: ប៊ុល ប៉ូរ៉ែន ជាមេផ្ទះ

## ខេត្តបាត់ដំបង



**សួគ៌ កែវពិពណ៌**

កើត: ០៦/០៩/១៩៩៧

វិទ្យាល័យព្រះមុនីវង្ស

ឪពុក: សេង សួរ

ជានគរបាល

ម្តាយ: ឈឹម ប៉េងចេង

ជាមន្ត្រីសុខាភិបាល



**ប្រសិត លក្ខណា**

កើត: ២៨/០៦/១៩៩៧

វិទ្យាល័យថ្មគោល

ឪពុក: អ៊ិត ប្រសិត

ជា គ្រូបង្រៀន

ម្តាយ: ឡាង សុមាលី

ជាគ្រូបង្រៀន

# យុវនារីនិទ្ទេស A

## ខេត្តបាត់ដំបង



**អ៊ួង មុនីរាសី**

កើត: ១៨/០១/១៩៩៧

វិទ្យាល័យ ព្រះមុនីវង្ស

ឪពុក: អ៊ួង ម៉ានី ជាវេជ្ជបណ្ឌិត

ម្ដាយ: សុក បូរាភិន

ជាវេជ្ជបណ្ឌិត



**គង់ មាសមល្លិកា**

កើត: ១០/១១/១៩៩៧

វិទ្យាល័យ អេស អូ អេស

ឪពុក: គង់ សុភាព

ជាគ្រូបង្រៀន

ម្ដាយ: មាស មាលតី ជាគ្រូពេទ្យ



**ភួង រតនៈវលី**

កើត:១៧/១២/១៩៩៧

វិទ្យាល័យ ពេជ្រចិន្តា

ឪពុក: ភួង ប៊ុនណាត

ជា កសិករ

ម្ដាយ: សុន ធារី ជាមេផ្ទះ

## តារាងសិស្សជាប់និទ្ទេសA

| ល.រ | ខេត្ត/ក្រុង | ស្រី | ប្រុស | សរុប | ល.រ | ខេត្ត/ក្រុង | ស្រី | ប្រុស | សរុប |
|---|---|---|---|---|---|---|---|---|---|
| ១ | ក្រុងភ្នំពេញ | ២១ | ២៧ | ៤៨ | ១៤ | ព្រះសីហនុ | ០ | ២ | ២ |
| ២ | សៀមរាប | ៦ | ៨ | ១៤ | ១៥ | ប៉ៃលិន | ០ | ១ | ១ |
| ៣ | បាត់ដំបង | ៥ | ២ | ៧ | ១៦ | ព្រៃវែង | ០ | ០ | ០ |
| ៤ | ត្បូងឃ្មុំ | ៥ | ១ | ៦ | ១៧ | កំពង់ចាម | ០ | ៥ | ៥ |
| ៥ | កំពត | ៣ | ១ | ៤ | ១៨ | កែប | ០ | ០ | ០ |
| ៦ | តាកែវ | ២ | ៤ | ៦ | ១៩ | មណ្ឌលគិរី | ០ | ០ | ០ |
| ៧ | កណ្ដាល | ២ | ៣ | ៥ | ២០ | រតនគិរី | ០ | ០ | ០ |
| ៨ | កំពង់ធំ | ១ | ១ | ២ | ២១ | កោះកុង | ០ | ០ | ០ |
| ៩ | ព្រះវិហារ | ១ | ១ | ២ | ២២ | ឧត្តរមានជ័យ | ០ | ០ | ០ |
| ១០ | បន្ទាយមានជ័យ | ១ | ១ | ២ | ២៣ | ស្ទឹងត្រែង | ០ | ០ | ០ |
| ១១ | ក្រចេះ | ១ | ១ | ២ | ២៤ | កំពង់ឆ្នាំង | ០ | ០ | ០ |
| ១២ | កំពង់ស្ពឺ | ១ | ០ | ១ | ២៥ | ពោធិសាត់ | ០ | ០ | ០ |
| ១៣ | ស្វាយរៀង | ០ | ១ | ១ | | | | | |
| | *សរុប* | | | | | | ៤៩នាក់ | ៥៩នាក់ | ១០៨ នាក់ |

# សន្និសីទពិភពលោក ស្តីពី ស្ត្រី




លោកជំទាវរដ្ឋមន្ត្រីបង្ហាញអំពីផែនការយុទ្ធសាស្ត្ររបស់ក្រសួងកិច្ចការនារីជូនថ្នាក់ដឹកនាំស្ត្រី នៃប្រទេសជប៉ុន

លោកជំទាវវេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារីបានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមសន្និសីទពិភពលោកស្តីពីស្ត្រី (WAW! 2015) នៅទីក្រុងតូក្យូ នៃប្រទេសជប៉ុន កាលពីថ្ងៃទី ២៨-២៩ ខែសីហា ឆ្នាំ២០១៥ ដើម្បីជជែកពិភាក្សា និងចែករំលែកបទពិសោធន៍ ស្តីពីការលើកកម្ពស់សិទ្ធិស្ត្រី និងស្វែងរកវិធីសាស្ត្រក្នុងការជម្រុញឱ្យមានសមភាព



លោកជំទាវរដ្ឋមន្ត្រីថតរូបអនុស្សាវរីយ៍ក្នុងសន្និសីទពិភពលោក នៅទីក្រុងតូក្យូ

រវាងបុរសនិងស្ត្រីនៅក្នុងវិស័យការងារ។

នៅក្នុងអង្គប្រជុំលោកជំទាវរដ្ឋមន្ត្រីបានលើកនូវចំណុចសំខាន់ៗ ដើម្បីពន្លឿនសមភាពយេនឌ័រ ដូចជា៖

-រដ្ឋាភិបាលតាំងពីថ្នាក់ដឹកនាំកំពូល ដល់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់មានឆន្ទៈនយោបាយក្នុងការលើកកម្ពស់សមភាពយេនឌ័រ ។

-ការស្រាវជ្រាវធ្វើដោយអង្គការអន្តរជាតិ និងឯកជន បានបង្ហាញឱ្យឃើញថា ការចូលរួមរបស់ស្ត្រីក្នុងវិស័យឯកជន ផ្សារភ្ជាប់ជាមួយនឹងកំណើនសេដ្ឋកិច្ចជាតិ ។

-បុរសត្រូវតែមានចំណែកទទួលខុសត្រូវក្នុងគ្រួសារ ក្នុងការអភិវឌ្ឍផ្នែកបញ្ញា ស្មារតី និងភាពជោគជ័យនៃការសិក្សារបស់កូន ព្រមទាំងកាត់បន្ថយភាពទំនើងនៃកូនប្រុស ។

-ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) ជាមធ្យោបាយសម្រួលដល់ការងាររបស់ស្ត្រីក្នុងការអភិវឌ្ឍសង្គម ។

-ភាពជោគជ័យនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG Goal 1-17 ក្នុងនោះ Goal 5 មានគោលដៅ ស្តីពីសមភាពយេនឌ័រផងដែរ) ។

# សន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពី ស្ត្រី លើកទី២ នៅទីក្រុងម៉ានីឡា




**លោកជំទាវរដ្ឋមន្ត្រី រាយការណ៍អំពីការងារដែលក្រសួងសម្រេចបាននៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ាន ស្តីពី ស្ត្រី**

សន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីស្ត្រីលើកទី២ បានប្រព្រឹត្តិទៅនាថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៥ នៅទីក្រុងម៉ានីឡា ប្រទេសហ្វីលីពីន ។

រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានរាយការណ៍អំពីការងារដែលក្រសួងសម្រេចបាន ក្នុងការអនុវត្តសេចក្តីថ្លែងការណ៍រួមរបស់សន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីស្ត្រីលើកទីមួយ (ឆ្នាំ២០១២ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ) ដែលពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ ក្នុងបម្រែបម្រួលអាកាសធាតុ និងធ្វើបទអន្តរាគមន៍ដែលពាក់ព័ន្ធនឹងប្រធានបទរបស់សន្និសីទស្តីពី " **សមិទ្ធិផលរបស់ប្រទេសកម្ពុជា ដើម្បីសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី នៅក្នុងទស្សនៈវិស័យឆ្នាំ២០២៥ របស់សហគមន៍អាស៊ាន** " ។




**លោកជំទាវរដ្ឋមន្ត្រីថតរូបអនុស្សាវរីយ៍ជាមួយ រដ្ឋមន្ត្រីនៃបណ្តាប្រទេសអាស៊ាន**

***អង្គប្រជុំបាន៖***

*-ឯកភាពជាគោលការណ៍លើផែនការសកម្មភាពថ្មីរបស់គណៈកម្មាធិការស្ត្រីអាស៊ាន (២០១៦-២០២០)។*

*-ចេញសេចក្តីថ្លែងការណ៍រួមរបស់សន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីស្ត្រីលើកទី២ ដែលជម្រុញឱ្យមានកិច្ចសហការរវាងស្ថាប័នឯកទេសនានា របស់អាស៊ាន ដើម្បីលើកកម្ពស់ការបញ្ជ្រាបយេនឌ័រទៅក្នុងសសរស្តម្ភទាំងបីរបស់អាស៊ាន៕*

# កិច្ចប្រជុំគណៈកម្មាធិការអាស៊ាន ស្តីពី ស្ត្រី



កិច្ចប្រជុំរវាងគណៈកម្មាធិការអាស៊ាន ស្តីពី ស្ត្រី (ACW) និងគណៈកម្មការអាស៊ាន ដើម្បីលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ដើម្បីផ្តល់យោបល់ចុងក្រោយលើផែនការសកម្មភាពថ្នាក់តំបន់ ស្តីពី ការលុបបំបាត់អំពើហិង្សាលើស្ត្រី (ទីក្រុងម៉ានីឡា ថ្ងៃទី២០ តុលា ឆ្នាំ២០១៥)។




កិច្ចប្រជុំលើកទី១៤ របស់គណៈកម្មាធិការអាស៊ានស្តីពី ស្ត្រី (ទីក្រុងម៉ានីឡា ថ្ងៃទី២១-២២ តុលា ឆ្នាំ២០១៥)

# កិច្ចប្រជុំចំនួនពីរ នៅលេខាធិការដ្ឋានអាស៊ានប្រចាំនៅទីក្រុងហ្សាកាតា



លោកជំទាវ ខេង សំវ៉ាដា រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី ថតរូបអនុស្សាវរីយ៍ជាមួយស្ត្រីថ្នាក់ដឹកនាំអាស៊ាន

លោកជំទាវ **ខេង សំវ៉ាដា** រដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី រួមជាមួយមន្ត្រីចំនួនពីររូបបានអញ្ជើញចូលរួមកិច្ចប្រជុំចំនួនពីរ នៅលេខាធិការដ្ឋានអាស៊ានប្រចាំនៅទីក្រុងហ្សាកាតា កាលពីថ្ងៃទី ២៤ដល់ថ្ងៃទី២៦ សីហា ឆ្នាំ២០១៥។

១. កិច្ចប្រជុំពិសេសរបស់ACW (**ASEAN Committee on Women ឬគណៈកម្មាធិការអាស៊ានស្តីពីស្ត្រី**) ៖ ដើម្បីរៀបចំផែនការសកម្មភាពថ្មីរបស់ ACW (២០១៦-២០២០) ដែលមានចំនួន៥ចំណុច៖ ស្ត្រីក្នុងភាពជាអ្នកដឹកនាំ / ការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថសង្គម / ការបញ្ជ្រាបយេនឌ័រទៅក្នុងសសរស្តម្ភទាំងបីរបស់អាស៊ាន / ការលុបបំបាត់អំពើហិង្សាលើស្ត្រីភេទ / ស្ត្រី និងភាពរឹងប៉ឹងផ្នែកសេដ្ឋកិច្ច ។

នៅពេលវិលត្រលប់មកប្រទេសវិញ ACW ទាំងអស់ត្រូវពិភាក្សាជាមួយថ្នាក់ដឹកនាំស្ថាប័នរបស់ខ្លួន ដើម្បីរៀបចំគម្រោងមួយ ឬពីរ សំរាប់ដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពថ្មីនេះ។

២.កិច្ចប្រជុំរវាង ACW និង ACWC គណៈកម្មការអាស៊ានដើម្បីលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមាររបស់ប្រទេសអាស៊ានទាំង១០ ដើម្បីពិនិត្យ និងកែសំរួលលើសេចក្តីព្រាង នៃផែនការសកម្មភាពថ្នាក់តំបន់ ស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី។ សេចក្តីព្រាងផែនការសកម្មភាពនេះ នឹងត្រូវដាក់សុំការអនុម័តរបស់ថ្នាក់ដឹកនាំប្រទេសអាស៊ានទាំងអស់ នៅក្នុងសន្និសីទកំពូលអាស៊ាន ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី នាខែវិច្ឆិកា ឆ្នាំ២០១៥៕

# កិច្ចប្រជុំចំនួនបី នៅលេខាធិការដ្ឋានអាស៊ាន



លោកជំទាវ **ឡុង សុផល្លី** រួមជាមួយប្រធាននាយកដ្ឋានមួយរូប បានទៅចូលរួមកិច្ចប្រជុំចំនួនបី នៅលេខាធិការដ្ឋានអាស៊ានប្រចាំ នៅទីក្រុងហ្សាកាតា ពីថ្ងៃទី២៦ ដល់ ២៩ ខែសីហា ឆ្នាំ២០១៥។

១. កិច្ចប្រជុំពិសេសរបស់គណៈកម្មការអាស៊ានដើម្បីលើកកម្ពស់ និងការពារសិទ្ធស្ត្រីនិងកុមារ (ACWC) សំដៅបង្កើតផែនការសកម្មភាពថ្មីរបស់ ACWC (២០១៦-២០២០) ដែលទាក់ទងនឹងសិទ្ធិស្ត្រី ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី / ការចូលរួមផ្នែកនយោបាយនិងភាពជាអ្នកដឹកនាំរបស់ស្ត្រី / ការបង្កើតនូវប្រព័ន្ធ ការពារកុមារនៅក្នុងអាស៊ាន ដើម្បីឆ្ពោះទៅរកការកាត់បន្ថយនៃអំពើហិង្សាលើកុមារ ធានាឱ្យបាននូវការរីកចំធាត់របស់កុមារ ការចុះសំបុត្រកំណើត និងការទទួលបាននូវការយក ចិត្តទុកដាក់ទាំងផ្នែកសុខភាពនិងការអប់រំ ផ្តល់ភាពអង់អាចដល់កុមារក្នុងការចូលរួមនានា និងសេចក្តីសម្រេចចិត្តទាក់ទងការរស់នៅរបស់គាត់។

នៅពេលវិលត្រឡប់មកប្រទេសវិញ ACWC ទាំងអស់ត្រូវពិភាក្សាជាមួយថ្នាក់ដឹកនាំស្ថាប័នរបស់ខ្លួន ដើម្បីរៀបចំគម្រោងមួយឬពីរសម្រាប់ដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពថ្មីនេះ។

២. កិច្ចប្រជុំរវាង ACW និង ACWC របស់ប្រទេសអាស៊ានទាំង១០ ដើម្បីពិនិត្យ និងកែសម្រួលលើសេចក្តីព្រាង នៃផែនការសកម្មភាពថ្នាក់តំបន់ ស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី។

៣. កិច្ចប្រជុំរវាង SOMSWD និង ACWC របស់ប្រទេសអាស៊ានទាំង១០ ដើម្បីពិនិត្យនិងកែសម្រួលលើសេចក្តីព្រាងផែនការសកម្មភាពថ្នាក់តំបន់ ស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ៕

# សកម្មភាពអន្តរជាតិសំខាន់ៗរបស់ថ្នាក់ដឹកនាំក្រសួងកិច្ចការនារី



ជំនួបរវាងលោកជំទាវវេជ្ជ, **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងឯកឧត្តម NuttaVudh Photisaro ឯកអគ្គរាជទូតព្រះរាជាណាចក្រ ថៃប្រចាំនៅកម្ពុជា



លោកជំទាវរដ្ឋមន្ត្រីជូនវត្ថុអនុស្សាវរីយ៍ឯកឧត្តមអគ្គរដ្ឋទូតឥណ្ឌា

លោកជំទាវវេជ្ជ, **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានអនុញ្ញាតឱ្យឯកឧត្តមអគ្គរដ្ឋទូតឥណ្ឌា Naveen Srivastava ជួបសម្តែងការគួរសមក្នុងអាណត្តិថ្មី ដែលឯកឧត្តមបានមកបំពេញភារៈកិច្ចនៅប្រទេសកម្ពុជា ។



លោកជំទាវរដ្ឋមន្ត្រីពិភាក្សាការងារជាមួយ
លោកជំទាវឯកអគ្គរដ្ឋទូតស៊ុយអែត

លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារីបានជួបពិភាក្សាការងារជាមួយលោកជំទាវ Anna Maj Hultgard ឯកអគ្គរដ្ឋទូតប្រទេសស៊ុយអែត ដើម្បីជម្រាបអំពីទិសដៅការងារបន្តរបស់ក្រសួងក្នុងកិច្ចសហប្រតិបត្តិការបន្ត លើការងារលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា និងពង្រឹងភាពអង់អាចដល់ស្ត្រី។



លោកជំទាវរដ្ឋមន្ត្រីពិភាក្សាការងារជាមួយលោកស្រីប្រធាន អង្គការឃៃរថ្មី

លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី បាន អនុញ្ញាតឱ្យលោកស្រី Tanya Bernfield ប្រធានអង្គការឃៃរថ្មីប្រចាំកម្ពុជា ចូលសម្តែងការគួរសម។



លោកជំទាវរដ្ឋមន្ត្រីពិភាក្សាការងារជាមួយ លោក Shaun Ellmers

លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី បាន អនុញ្ញាតឱ្យលោក Shaun Ellmers ជួបសម្តែងការគួរសមក្នុងកិច្ចសហប្រតិបត្តិការរវាងក្រសួងកិច្ចការនារី និង EVAW ដែលមានរយៈពេល៣ឆ្នាំ ដែលធ្វើលើគម្រោងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។



លោកជំទាវ ឃឹម ចំរើន ពិភាក្សាការងារ ជាមួយលោក Alassane Saw

លោកជំទាវ **ឃឹម ចំរើន** រដ្ឋលេខាធិការក្រសួងកិច្ចការនារី ជួបពិភាក្សាការងារជាមួយលោក Alassane Saw នាយកធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា គោលបំណងពិភាក្សាការងារទាក់ទងនឹងវិស័យ អាទិភាព និងការអភិវឌ្ឍរបស់កម្ពុជា។

## ពិធីចុះអនុស្សរណៈយោគយល់គ្នា លើគំរោងសហប្រតិបត្តិការ រវាងក្រសួងកិច្ចការនារី និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីកូរ៉េ




លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងលោកស្រីបណ្ឌិត **MYUNG SUN LEE** ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីកូរ៉េ បានចុះអនុស្សរណៈយោគយល់គ្នាលើគម្រោងសហប្រតិបត្តិការរយៈពេល៥ឆ្នាំ កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ នៅរាជធានីភ្នំពេញ។ គម្រោងនឹងមានសកម្មភាពសំខាន់ៗដូចជា ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ វគ្គបណ្តុះបណ្តាល និងការស្រាវជ្រាវ ដើម្បីលើកកំពស់សមធម៌យេនឌ័រ៕

## សិក្ខាសាលា ស្តីពី ការប៉ាន់ប្រមាណសមត្ថភាពក្រសួង-ស្ថាប័នពាក់ព័ន្ធ



កាលពីថ្ងៃទី៣០ ដល់ ៣១ ខែកក្កដា ឆ្នាំ ២០១៥ នៅសណ្ឋាគារ Golden sea ខេត្ត ព្រះសីហនុ ក្រសួងកិច្ចការនារី បានរៀបចំសិក្ខាសាលា ក្រោម អធិបតីភាពលោកជំទាវវេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ស្តីពី ការប៉ាន់ប្រមាណ សមត្ថភាព ក្រសួង-ស្ថាប័នពាក់ពន្ធ័ ដើម្បីបញ្ជ្រាបយេនឌ័រតាមវិស័យ ដោយមានអ្នកចូលរួមចំនួន ៧៥នាក់ ស្រី ៤៧នាក់៕

# កម្មវិធីបំប៉នជំនាញភាពជាអ្នកដឹកនាំ សម្រាប់ស្ត្រីនៅអាស៊ីលើកទី២




នៅថ្ងៃទី២ វិច្ឆិកា ២០១៥ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សហការជាមួយក្រសួងកិច្ចការនារី បានរៀបចំកម្មវិធីបំប៉នជំនាញភាពជាអ្នកដឹកនាំសំរាប់ស្ត្រីនៅអាស៊ីលើកទី២ ដើម្បីជួយដល់ស្ត្រីជាមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ចំនួន២៥រូប មកពី១៦ប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច ដើម្បីក្លាយជាអ្នកដឹកនាំនាពេលអនាគត។ កម្មវិធីដែលមានរយៈពេល៤ថ្ងៃ នឹងបង្រៀនអំពីវិធីកសាងទំនុកចិត្តផ្ទាល់ខ្លួន ការបណ្តុះបណ្តាលអំពីការប្រាស្រ័យទាក់ទងជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ ការចែករំលែកបទពិសោធន៍ ការបង្កើតបណ្តាញ និងការបង្កើតសម្ព័ន្ធភាពការងារ។

លោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានមានប្រសាសន៍ថា ព្រឹត្តិការណ៍នេះពិតជាឆ្លើយតបទៅនឹងការយកចិត្តទុកដាក់របស់ប្រទេសកម្ពុជាលើការជំរុញឱ្យចំនួនស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ និងអ្នកធ្វើសេចក្តីសម្រេចមានការកើនឡើង នៅគ្រប់កម្រិតទាំងអស់ក្នុងជួររដ្ឋាភិបាល។

ធនាគារអភិវឌ្ឍន៍អាស៊ីមានគំនិតផ្តួចផ្តើមជាច្រើន ដើម្បីកាត់បន្ថយគម្លាតយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិច៕




លោកជំទាវថ្នាក់ដឹកនាំក្រសួងកិច្ចការនារីថតរូបអនុស្សាវរីយ៍ជាមួយស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច

# វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំផែនការថវិកាដែលឆ្លើយតបនឹងយេនឌ័រ




លោកជំទាវ **ឃឹម ចំរើន** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី បានចូលរួមបើកវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំផែនការថវិកាដែលឆ្លើយតបនឹងយេនឌ័រ ក្រោមការជួយឧបត្ថម្ភរបស់អង្គការ UNDP នៅសណ្ឋាគារប្រេស៊ីដង់ ខេត្តបាត់ដំបង នាថ្ងៃទី២៨-៣០ ខែកក្កដា ឆ្នាំ២០១៥ ។ វគ្គបណ្តុះបណ្តាលមានគោលបំណងផ្តល់នូវចំណេះដឹងក្នុងការរៀបចំថវិកាឱ្យឆ្លើយតបទៅនឹងយេនឌ័រ ដោយផ្សារភ្ជាប់គោលនយោបាយយេនឌ័រទៅនឹងថវិកា។ សមាសភាពចូលរួមមាន៖ តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍សរុបចំនួន ៦៥នាក់ (ស្ត្រី៤៩នាក់) ។ សិក្ខាកាមបានពិភាក្សាពីច្បាប់ គោលនយោបាយ កម្មវិធី ក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងប្រទេសកម្ពុជា និងការបញ្ជ្រាបយេនឌ័រលើផែនការថវិកាឆ្នាំ២០១៦ របស់ខ្លួន។



*សិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំផែនការថវិកាដែលឆ្លើយតបនឹងយេនឌ័រ*

# សកម្មភាពទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា



លោកជំទាវ ប៊ុន ពុទ្ធី អនុរដ្ឋលេខាធិការ ថតរូបអនុស្សាវរីយ៍ជាមួយសិក្ខាកាមនៅខេត្តសៀមរាប

តាំងពីដើមឆ្នាំ២០១៥ រហូតដល់បច្ចុប្បន្ន នាយកដ្ឋានការពារផ្លូវច្បាប់ នៃអគ្គនាយកដ្ឋានអភិវឌ្ឍសង្គម បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី សកម្មភាពថ្នាក់ភូមិ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានាចំនួន ៣វគ្គ នៅខេត្តក្រចេះ សៀមរាប និងខេត្តកំពង់ឆ្នាំង ។ គោលបំណងនៃវគ្គ គឺសំដៅពង្រឹងសមត្ថភាពដល់មន្ត្រីមន្ទីរកិច្ចការនារីថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទូទាំង ២៥ រាជធានី ខេត្ត សរុបចំនួន៩០នាក់ (ស្ត្រី៨៩នាក់) ឱ្យធ្វើការអប់រំបន្តដល់ប្រជាជន រួមគ្នាទប់ស្កាត់ការជួញដូរមនុស្សនៅមូលដ្ឋានរបស់ខ្លួន។




ផ្សព្វផ្សាយសកម្មភាពថ្នាក់ភូមិនៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

បន្ទាប់ពីបញ្ចប់វគ្គ សិក្ខាកាមបានយកចំណេះដឹងទៅធ្វើការប្រជុំផ្សព្វផ្សាយបន្តដល់ប្រជាជននៅតាមភូមិ ឃុំ ស្រុកគោលដៅ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនអំពីគ្រោះថ្នាក់ នៃអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ប្រជាជនចូលរួមសរុបចំនួន ៦០០នាក់ (ស្ត្រី៤២៩នាក់) តំណាងឱ្យ ៦០០ គ្រួសារ ៕

# ៣០នាក់នឹងក្លាយជាគ្រូបង្គោលទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ

មន្រ្តី៣០រូបត្រូវបានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះតាមរយៈផ្ទាំងរូបភាព និងខ្សែវីដេអូរយៈពេលបីថ្ងៃ នៅខេត្តសៀមរាប។ វគ្គសិក្សាដែលរៀបចំដោយនាយកដ្ឋានការពារផ្លូវច្បាប់របស់ក្រសួងកិច្ចការនារី ប្រព្រឹត្តទៅក្រោមការចូលរួមពី លោកជំទាវ **ទេស ច័ន្ទសារឿន** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និងលោកស្រី **ឃូ សុនា** អភិបាលរងនៃគណៈអភិបាល ខេត្តសៀមរាប ។

សិក្ខាកាមទាំង៣០នាក់ (ប្រុស២នាក់) ដែលជាមន្រ្តីមកពីមន្ទីរកិច្ចការនារីស្រុក ខេត្តពោធិសាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ កំពង់ធំ និងខេត្តសៀមរាប នឹងធ្វើជាគ្រូបង្គោលធ្វើការផ្សព្វផ្សាយអប់រំបន្តដល់ប្រជាពលរដ្ឋតាមមូលដ្ឋានសហគមន៍ប្រកបដោយប្រសិទ្ធភាព។

លោកជំទាវ **ទេស ច័ន្ទសារឿន** បានមានប្រសាសន៍ថា អំពើហិង្សាក្នុងគ្រួសារជាអំពើមួយដែលយើងទាំងអស់គ្នាមិនអាចទទួលយកបាន។ ប៉ុន្តែដំណើរការលុបបំបាត់អំពើហិង្សាវាមិនអាចធ្វើទៅបានទេ ប្រសិនបើវាខ្វះការចូលរួមពីយើងទាំងអស់គ្នា ពីព្រោះបញ្ហាតែងតែកើតឡើងនៅតាមសហគមន៍មូលដ្ឋានរបស់យើងតែម្តង ។លោកជំទាវសង្ឃឹមថាឆ្លងកាត់វគ្គនេះ សិក្ខាកាមទាំងអស់ នឹងក្លាយទៅជាគ្រូបង្គោលដ៏ល្អឈានមុខគេក្នុងការរួមចំណែកទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលភាគច្រើនជាស្រ្តី និងកុមារ។

ក្រោយវគ្គបណ្តុះបណ្តាល គ្រូបង្គោលបានចុះផ្សព្វផ្សាយផ្ទាល់ក្នុងឃុំដូនពេង និងឃុំតាសោម ស្រុកអង្គរជុំ មានប្រជាពលរដ្ឋចូលរួមចំនួន ៤៨៣នាក់ (ស្រ្តី៣០៨នាក់) ៕ ***ស្រីពេជ្រ***



គណៈអធិបតីថតរូបអនុស្សាវរីយ៍ជាមួយសិក្ខាកាមនៅខេត្តសៀមរាប

# វគ្គបណ្តុះបណ្តាលស្តីពីការទប់ស្កាត់អំពើរំលោភសេពសន្ថវៈលើស្ត្រីនិងកុមារ



គណៈអធិបតីថតរូបអនុស្សាវរីយ៍ជាមួយសិក្ខាកាមនៅខេត្តតាកែវ

វគ្គបណ្តុះបណ្តាលស្តីពីការទប់ស្កាត់អំពើរំលោភសេពសន្ថវៈលើស្ត្រីនិងកុមារ បានធ្វើចំនួន ៣ដង នៅខេត្តមណ្ឌលគីរី ឧត្តរមានជ័យ និងខេត្តតាកែវ ក្នុងគោលបំណងផ្តល់ចំណេះដឹង និងបទពិសោធន៍ដល់មន្ត្រីថ្នាក់ខេត្ត ស្រុក ខណ្ឌ ក្នុងការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារនៅកម្ពុជាឱ្យមានប្រសិទ្ធភាពនិងជួយជនរងគ្រោះទាន់ពេលវេលា។អ្នកចូលរួមជាជនបង្គោលមកពីមន្ទីរកិច្ចការនារីខេត្ត ក្រុង ស្រុក ខណ្ឌ ទូទាំង២៥ ខេត្ត-រាជធានី សរុបចំនួន ១៣៥នាក់ (ស្ត្រី ១២០នាក់)។

## សកម្មភាពទប់ស្កាត់អំពើរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ



សិក្ខាកាមអនុវត្តសាកល្បងនៅមន្ទីរកិច្ចការនារីខេត្តតាកែវ

បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល សិក្ខាកាមទាំងអស់ បានចុះទៅធ្វើការប្រជុំផ្សព្វផ្សាយសាកល្បងសកម្មភាពទប់ស្កាត់អំពើរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ នៅ តាមឃុំចំនួន១២ របស់ស្រុកគោលដៅចំនួន ៦ស្រុក មានប្រជាពលរដ្ឋចូលរួមសរុប ៩០០នាក់ (ស្ត្រី ៨៤៧ នាក់)៕

# វេទិកា ស្តីពីបញ្ហាប្រឈមរបស់យុវវ័យនៅក្នុងសង្គម



លោកជំទាវ អ៊ឹម ស៊ីថៃ រដ្ឋលេខាធិការក្រសួងកិច្ចការនារី ជាអធិបតីភាពក្នុងវេទិកាស្តីពី បញ្ហាប្រឈមរបស់យុវវ័យនៅក្នុងសង្គម

នាយកដ្ឋានស្ត្រី និងការអប់រំបានរៀបចំវេទិកានៅតាមសាលាចំនួន៩ របស់ខេត្តព្រៃវែង កំពត និងខេត្តព្រះវិហារ ស្តីពីបញ្ហាប្រឈម របស់យុវវ័យនៅក្នុងសង្គម ដើម្បីបង្កើនការយល់ដឹងពីសីលធម៌សង្គម និងកាត់បន្ថយ នូវទស្សនៈ ឥរិយាបថខុសឆ្គងរបស់យុវវ័យ ដែលមានការចូលរួមរបស់សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ សរុបចំនួន១,៩៤២ នាក់ (ស្ត្រី១,១៣៦ នាក់) ។

# វិធីសាស្ត្របង្រៀនមនុស្សពេញវ័យ



វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀន មនុស្សចាស់នៅខេត្តកំពង់ឆ្នាំង



ពិធីបើកថ្នាក់អក្ខរកម្មដល់កម្មករ កម្មការិនីនៅតាម សហគមន៍ក្នុងខេត្តកំពង់ឆ្នាំង

វគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្ត្របង្រៀនមនុស្សពេញវ័យ បានរៀបចំធ្វើនៅខេត្តកំពង់ឆ្នាំង ដើម្បីពង្រឹងសមត្ថភាពគ្រូជាប់កិច្ចសន្យាក្នុងការបង្រៀនអក្ខរកម្មដល់កម្មករ កម្មការិនីរោងចក្រចំនួន ២៥នាក់ (ស្ត្រី១៥នាក់)។

# ការបញ្ជ្រាបយេនឌ័រនៅក្នុងការរៀបចំផែនការគម្រោងកម្មវិធី





លោកជំទាវ ច័ន្ទ សូរីយ៍ រដ្ឋលេខាធិការ មានមតិផ្តាំផ្ញើទៅកាន់សិក្ខាកាម

វគ្គបណ្តុះបណ្តាលស្តីពី ការបញ្ជ្រាបយេនឌ័រទៅក្នុងការរៀបចំផែនការគម្រោងកម្មវិធី តាមវិធីសាស្ត្រការគ្រប់គ្រងវដ្ត នៃគម្រោងត្រូវបានរៀបចំ ចំនួន៣វគ្គ នៅខេត្ត បាត់ដំបង តាកែវ និងខេត្តមណ្ឌលគីរី ។ គោលបំណងនៃវគ្គគឺដើម្បីបង្កើនសមត្ថភាពមន្ត្រីថ្នាក់ក្រសួងមន្ទីរកិច្ចការនារីខេត្ត ក្រុង ស្រុក ខណ្ឌ ឱ្យយល់ច្បាស់ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្លើយតបនឹងយេនឌ័រ និងមានសមត្ថភាពក្នុងការរៀបចំផែនការគម្រោងកម្មវិធី តាមវិធីសាស្ត្រការគ្រប់គ្រងវដ្តនៃគម្រោង ឱ្យឆ្លើយតបនឹងយេនឌ័រ ។ សមាសសភាពចូលរួមមានចំនួន ៩២នាក់ (ស្ត្រី ៦៦នាក់) មកពីក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីខេត្ត ក្រុង ស្រុក ខណ្ឌ ចំនួន ១៩ខេត្ត៖ ខេត្តបាត់ដំបង ប៉ៃលិន ពោធិសាត់ បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ តាកែវ កំពត កែប កំពង់ស្ពឺ កោះកុង ព្រះសីហនុមណ្ឌលគីរី រតនគីរីក្រចេះ ស្ទឹងត្រែង កំពង់ធំ កំពង់ចាម និងខេត្តត្បូងឃ្មុំ ៕



គណៈអធិបតីថតរូបអនុស្សាវរីយ៍ជាមួយសិក្ខាកាមនៅខេត្តតាកែវ

# វេទិកា យុវជន រួមគ្នាទប់ស្កាត់អំពើហិង្សាលើស្ត្រី

រៀបចំវេទិកា យុវជនរួមគ្នាទប់ស្កាត់អំពើហិង្សាលើស្ត្រីបានចំនួន ៩ វិទ្យាល័យ នៅខេត្តកំពង់ចាម កំពង់ស្ពឺ និងខេត្តកំពត ក្នុងគោលបំណងបង្កើនការយល់ដឹងរបស់យុវវ័យ រួមគ្នាកាត់បន្ថយអំពើហិង្សាលើស្ត្រី និងកុមារ ដើម្បីឈានទៅរកគ្រួសារមួយមានសុភមង្គល។ អ្នកចូលរួមមាននាយកសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សសរុបចំនួន ១,៣៥០នាក់ ក្នុងនោះស្ត្រី ៨២៦នាក់៕



លោកជំទាវ ឡុង សុផល្លី អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី ជាអធិបតីភាពក្នុងវេទិកាវិទ្យាល័យហ៊ុនសែនអង្គសុភី ខេត្តកំពត



គណៈអធិបតីថតរូបអនុស្សាវរីយ៍ជាមួយសិស្សវិទ្យាល័យព្រះរាជសម្ភារ ខេត្តកំពត









គណៈអធិបតីថតរូបអនុស្សាវរីយជាមួយសិស្សវិទ្យាល័យន.រណឫទ្ធិ-គន្ធបុប្ផា ខេត្តកំពង់ចាម

# ពីមន្ត្រីសាលាខេត្ត ឈានដល់អភិបាលក្រុងច្បារមន ខេត្តកំពង់ស្ពឺ



ការអភិវឌ្ឍសមត្ថភាព ដើម្បីឈានទៅរកជោគជ័យក្នុងជីវិតជាកត្តាសំខាន់សម្រាប់បុគ្គលគ្រប់រូប។

ការទទួលខុសត្រូវការងារគួបផ្សំជាមួយនឹងការតស៊ូព្យាយាមរៀនសូត្របង្កើនចំណេះដឹងបន្ថែម បានធ្វើឱ្យលោកស្រី **ប៉ោក សេដ្ឋា** ឈានពីមន្ត្រីធម្មតាក្លាយជាអភិបាលក្រុង ។

លោកស្រីបានចូលបម្រើការងារដំបូងនៅឆ្នាំ ១៩៧៩ ជាមន្ត្រីសាលាខេត្តកំពង់ស្ពឺ និងបានឡើងតួនាទីជាបន្តបន្ទាប់ រហូតដល់បច្ចុប្បន្នទទួលបានតួនាទីជាអភិបាលក្រុងច្បារមនខេត្តកំពង់ស្ពឺ។

ក្នុងតួនាទីជាថ្នាក់ដឹកនាំ លោកស្រីបានលះបង់កម្លាំងកាយចិត្ត និងថវិកាផ្ទាល់ខ្លួនមួយចំនួន ដើម្បីរួមចំណែកបម្រើប្រជាជនក្នុងមូលដ្ឋាន ដូចជាការងារកាកបាទក្រហម ចុះសួរសុខទុក្ខ និងចែកអំណោយជូនប្រជាពលរដ្ឋជួបបញ្ហា ដូចជា គ្រោះមហន្តរាយដោយភ្លើងឆេះផ្ទះ ទឹកជំនន់ គ្រោះរាំងស្ងួត ប្រជាពលរដ្ឋទីទ័លក្រីក្រ ចាស់ជរាគ្មានទីពឹង និងជនពិការជាដើម ។ នៅពេលមានបញ្ហាអសន្តិសុខកើតឡើងក្នុងមូលដ្ឋាន លោកស្រីបានចុះប្រឡូកជាមួយកងកម្លាំងប្រដាប់អាវុធជានិច្ច ដើម្បីធ្វើអន្តរាគមន៍មិនថាយប់ ឬថ្ងៃឡើយ ដូចជាករណីអំពើហិង្សាក្នុងគ្រួសារ ការចុះចាប់គ្រឿងញៀន និងចាប់ក្មេងស្ទាវវាយតប់គ្នា ។ ជាមួយគ្នានេះដែរ លោកស្រីបានប្រើប្រាស់គម្រោងថវិកាជាតិ និងគម្រោងថវិកាមូលនិធិឃុំសង្កាត់ ចូលរួមកសាងផ្លូវចាក់បេតុង ក្រាលគ្រួសក្រហម ធ្វើប្រពន្ធ័លូ និងស្ពានក្នុងខេត្ត ។ ក្រៅពីការងារមនុស្សធម៌ និងការងារអភិវឌ្ឍន៍ លោកស្រីបានផ្សព្វផ្សាយពីគោលនយោបាយភូមិឃុំមានសុវត្ថិភាពគ្រប់សង្កាត់ និងបានធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋគ្រប់ៗគ្នា។

លោកស្រីបានបន្តទៀតថា ការទទួលបានជោគជ័យក្នុងការងារ មានកត្តាពីរយ៉ាងគឺ កត្តាខាងក្នុង និងកត្តាខាងក្រៅ ។ កត្តាខាងក្នុងគឺអាស្រ័យដោយមានការគាំទ្រពីស្វាមី និងសមាជិកគ្រួសារ ពួកគាត់បានជួយរំលែកការងារផ្ទះសម្បែង ទើបខ្ញុំមានពេលវេលាគ្រប់គ្រាន់ក្នុងការបំពេញការងារបានរលូន ។ កត្តាខាងក្រៅគឺដោយសារមានការគាំទ្រពីថ្នាក់ដឹកនាំខេត្តជាពិសេស ប្រមុខរាជរដ្ឋាភិបាលដែលយកចិត្តទុកដាក់លើកកម្ពស់សមភាពយេនឌ័រជាពិសេសផ្តល់ឱកាសឱ្យស្ត្រីដែលមានសមត្ថភាពទទួលបានឋានៈតួនាទីសមរម្យនៅក្នុងសង្គម។

លោកស្រីមានកូន៧នាក់ (ស្ត្រី១នាក់)និងមានស្វាមីជាសមាជិកក្រុមប្រឹក្សាឃុំ៕

# ស្ត្រីដែលជាប់ជាប្រធានសង្កាត់រហូតតាំងពីការបោះឆ្នោតឆ្នាំ២០០២



លោកស្រី គា ថាវី
សំណេះសំណាលជាមួយប្រជាពលរដ្ឋ
ក្នុងការកសាងផ្លូវលំ

ក្នុងវ័យ៥៥ឆ្នាំលោកស្រី **គា ថាវី** បានជាប់ជាចៅសង្កាត់ទួលតាឯក ខេត្តបាត់ដំបងចំនួនបីអាណត្តិបន្តបន្ទាប់គ្នាចាប់តាំងពីការបោះឆ្នោតក្រុមប្រឹក្សាសង្កាត់លើកដំបូងនាឆ្នាំ២០០២ រហូតដល់បច្ចុប្បន្ន។

មុនឆ្នាំ២០០២ លោកស្រីជាអនុប្រធានសមាគមនារី ទីរួមខេត្តបាត់ដំបង ។ លោកស្រី **គា ថាវី** បានឱ្យដឹងថាការទទួលបានជោគជ័យលើការងារកន្លងមកនេះអាស្រ័យដោយមានការលើកទឹកចិត្ត និងគាំទ្រយ៉ាងពេញទំហឹងពី ស្វាមី ក្រុមគ្រួសារ បងប្អូន ប្រជាពលរដ្ឋ មន្ទីរកិច្ចការនារីខេត្ត និងមិត្តភក្តិ។

លោកស្រីតែងតែយកចិត្តទុកដាក់ដឹកនាំចលនានារីសង្កាត់ ហើយមានស្មារតីទទួលខុសត្រូវប្រកបដោយភាពអំណត់អត់ធ្មត់ ឧស្សាហ៍ព្យាយាមតស៊ូលះបង់ខ្ពស់ មានភាពស្មោះត្រង់ និងអធ្យាស្រ័យទូលាយ ធ្វើឲ្យលោកស្រីទទួលបាននូវការស្រឡាញ់គាំទ្រពីបងប្អូនប្រជាពលរដ្ឋក្នុងសង្កាត់។

ក្នុងតួនាទីជាចៅសង្កាត់ លោកស្រី **គា ថាវី** មានស្នាដៃជាច្រើន និងបានចូលរួមយ៉ាងសកម្មក្នុងការងារសង្គម ដូចជា ការពង្រឹងសមត្ថភាពនារីជាថ្នាក់ដឹកនាំភូមិ ការចុះអប់រំប្រជាពលរដ្ឋក្នុងមូលដ្ឋានឲ្យយល់ដឹងពីច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះច្បាប់ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ផលវិបាកនៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ព្រមទាំងចុះអប់រំផ្សព្វផ្សាយដល់ស្ត្រីដែលមានផ្ទៃពោះត្រូវទៅពិនិត្យផ្ទៃពោះឲ្យបានទៀងទាត់ដើម្បីធានាបាននូវ

សុខភាពល្អទាំងម្ដាយនិងទារកក្នុងផ្ទៃ អប់រំផ្សព្វ-ផ្សាយទប់ស្កាត់ការរីករាលដាលនៃជម្ងឺអេដស៍ និងមេរោគអេដស៍ និងអប់រំដល់ប្រជាពលរដ្ឋពីរបៀបថែទាំបរិស្ថានឱ្យបានស្អាតក្នុងសហគមន៍។

ជាពិសេសលោកស្រីបានដឹកនាំប្រជាជនយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ធ្វើឱ្យសង្កាត់ស្វាយប៉ោនេះទទួលចំណាត់ថ្នាក់លេខ១ទូទាំងខេត្ត ចាប់ពីឆ្នាំ២០១០ រហូតដល់ឆ្នាំ២០១៤។

លោកស្រី **គា ថាវី** បានស្វែងរកថវិកាជាតិ និងទំនាក់ទំនងជាមួយអង្គការ និងសប្បុរសជននានាមកកសាង បាននូវសមិទ្ធផលមួយចំនួនមានដូចជា ផ្លូវលំ ផ្លូវកៅស៊ូ ផ្លូវបេតុង បានប្រមាណ ២០ខ្សែ ប្រឡាយ១០ខ្សែ សាលារៀន២ខ្នងមានចំនួន២០បន្ទប់ សាលាសង្កាត់១កន្លែង វត្តអារាម ២កន្លែង មណ្ឌលសុខភាពមួយកន្លែង ហើយបានចងក្រងជម្រកបណ្ដោះអាសន្នជូនប្រជាជនដែលគ្មានផ្ទះសម្បែងបាន៦សហគមន៍ និងរកដីឱ្យប្រជាពលរដ្ឋសង់ផ្ទះស្នាក់នៅ និងធ្វើប័ណ្ណកម្មសិទ្ធជូនពួកគាត់បានចំនួន ២៥គ្រួសារ។



សកម្មភាពមនុស្សធម៌

អាស្រ័យដោយការខិតខំប្រឹងប្រែងប្រកបដោយស្មារតីទទួលខុសត្រូវ និងការលះបង់គ្រប់បែបយ៉ាង ទើបរាជរដ្ឋាភិបាលបានប្រគល់នូវគ្រឿងឥស្សរិយសមេដាយមុនីសារាភ័ណ្ឌថ្នាក់វឌ្ឍនាជូនលោកស្រី **គា ថាវី** ចំនួន១គ្រឿង មេដាយមុនីសារាភ័ណ្ឌថ្នាក់អស្សឫទ្ធិចំនួន១គ្រឿង និងមេដាយមាសការងារ ចំនួន ១គ្រឿង។

លោកស្រី **វិសុទ្ធ រដ្ឋា** អនុប្រធានមន្ទីរកិច្ចការនារីខេត្តបាត់ដំបងបានលើកឡើងថា កត្តាដែលលោកស្រី **គា ថាវី** ឈរជាចៅសង្កាត់បាន៣អាណត្តិជាប់ៗគ្នា ព្រោះទី១គាត់មានប្រជាប្រិយភាព ទី២មានការតស៊ូអត់ធ្មត់ ទី៣ មានទំនុកចិត្តជឿជាក់លើខ្លួនឯង មានបទពិសោធន៍ និងសមត្ថភាព ។

លោក **ទូច អង្គារិទ្ធ** ជាមន្ត្រីសង្កាត់ស្វាយប៉ោះ បានជាខ្ញុំគាំទ្រលោកស្រី **គា ថាវី** ជាប់មេឃុំបាន៣អាណត្តិនោះគឺដោយសារគាត់មានឆន្ទៈនិងលះបង់កម្លាំងកាយចិត្តពេលវេលាដើម្បីប្រជាពលរដ្ឋ ហើយជួយដោះស្រាយបញ្ហាផ្សេងៗជូនប្រជាពលរដ្ឋក្នុងសង្កាត់បានទាន់ពេលវេលា ធ្វើឱ្យប្រជាពលរដ្ឋក្នុងសង្កាត់គោរពស្រឡាញ់។

លោក **ម៉េង ឧត្តរា** ជាប្រជាពលរដ្ឋ៖ បានជាខ្ញុំគាំទ្រលោកស្រី **គា ថាវី** ឱ្យជាប់ជាចៅសង្កាត់៣អាណត្តិ ព្រោះគាត់ជាមនុស្សស្រីមួយរូប ដែលមានចិត្តទូលាយមិនប្រកាន់វណ្ណៈ មិនរើសអើងជួយដល់ប្រជាពលរដ្ឋក្រីក្រ គិតប្រយោជន៍រួមជាធំដើម្បីសេចក្ដីសុខរបស់ប្រជាពលរដ្ឋក្នុងសង្កាត់៕

*អ៊ុង ខេមរា*

# ស្ត្រី និងសិប្បកម្មហូល



តាមបណ្តោយផ្លូវជាតិលេខ២ ចូលតាមផ្លូវទៅភ្នំតាម៉ៅ ប្រជាជនភាគច្រើនផលិតហូលផាមួងតាមបែបប្រពៃណីតាំងពីដូនតា ក្រោយពីការងារស្រែចំការ។

លោកស្រី **ភ្លុច សុផាន្នី** បានឱ្យដឹងថា គាត់ប្រកបមុខរបរត្បាញហូលនេះក្នុងកំឡុងឆ្នាំ១៩៩០។ ការងារតម្បាញហូលនេះ ជួបការលំបាកខ្លះៗដោយសារខ្វះដើមទុន រីឯវត្ថុធាតុដើម ដូចជាសូត្រ និងល័ក្ខជ្រលក់ពណ៌ត្រូវយកពីឈ្មួញកណ្តាល ហើយហូលដែលផលិតបានត្រូវលក់ឱ្យឈ្មួញកណ្តាលវិញ ដូច្នេះលក់មិនបានថ្លៃទេ ក្នុង១ក្បិនសល់ត្រឹម១០ ទៅ១៥ ម៉ឺនរៀលតែប៉ុណ្ណោះ។

ស្ថិតក្នុងទឹកមុខញញឹមរួសរាយរាក់ទាក់ និយាយមួយៗជាមួយនិងការងារតម្បាញយ៉ាងមមាញឹក លោកយាយ **ទេប ខាប់** អាយុ ៧៧ឆ្នាំ បានលើកឡើងថា គាត់ប្រកបមុខរបរនេះតាំងពីអាយុ១៥ឆ្នាំ។ គ្រួសារគាត់ត្បាញហូលផាមួងតាំងពីដូនតាមកម្លេះ ព្រោះមុខរបរនេះស្រាលអាចមើលថែទាំកូនចៅ មើលផ្ទះសម្បែងហើយទទួលបានប្រាក់កម្រៃបន្តិចបន្តួចសម្រាប់ចិញ្ចឹមគ្រួសារទៀត។ ការងារត្បាញហូលនេះ បច្ចុប្បន្នប្រជាជនឈប់ធ្វើអស់មួយចំនួនធំហើយ ព្រោះហូលមានតម្លៃថោកពេក ហើយក្នុង១ក្បិនត្រូវចំណាយពេលពី៧ទៅ១០ថ្ងៃ អ្នកខ្លះដល់ទៅ ១៥ថ្ងៃ ហើយទទួលបាន ប្រាក់ចំណេញមកវិញត្រឹម តែ១០ទៅ១៥ ម៉ឺនរៀលតែប៉ុណ្ណោះអាស្រ័យទៅតាមទឹកដៃ។

ប្អូនស្រី **ញ៉ន សុភ័ក្ត** បានឱ្យដឹងថា ខ្ញុំទើបតែចាប់ផ្តើមប្រកបមុខរបរត្បាញហូលនេះទេ ដោយសារគាត់មានកូនតូច មិនអាចទៅធ្វើការងារនៅរោងចក្របាន ការងារត្បាញហូលនេះជួបការលំបាកខ្លាំងណាស់ ត្រូវតស៊ូព្យាយាមអត់ធ្មត់ ចំណាយពេលវេលាច្រើនចាប់ពី១៥ថ្ងៃឡើងទៅទើបបានហូល១ក្បិន។

លោក **ខឹម ហុល** មេឃុំស្លា បានឱ្យដឹងថា ប្រជាពលរដ្ឋនៅឃុំនេះ ប្រហែល៩០% ជាអ្នកត្បាញហូល ព្រោះជាមុខរបរប្រពៃណីតាំងពីដូនតាមកម្លេះ។ ក្នុងកំឡុងឆ្នាំ២០០៨ ក្នុង១ឃុំមានដល់ទៅ១៩០០កីតម្បាញ បន្ទាប់មកក្រោយមានវិបត្តិសេដ្ឋ-កិច្ចពិភពលោក តម្លៃហូលមានការធ្លាក់ចុះយ៉ាងខ្លាំងធ្វើឱ្យប្រជាពលរដ្ឋនៅទីនោះបោះបង់ការងារតម្បាញ ហើយចាប់យកមុខរបរការងារខាងក្រៅ ដូចជា ទៅធ្វើការងារនៅរោងចក្រកាត់ដេរ និងកម្មករសំណង់ជាដើម ហើយបច្ចុប្បន្នក្នុងឃុំស្លាកីតម្បាញនៅសល់ត្រឹម៦០០ ទៅ ៧០០តែប៉ុណ្ណោះ។ លោកមេឃុំមានការព្រួយបារម្ភយ៉ាងខ្លាំង ដោយខ្លាចទៅថ្ងៃអនាគត ប្រជាពលរដ្ឋបោះបង់មុខរបរនេះចោលទាំងស្រុង ធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ប្រពៃណីជាតិ ព្រោះសម្លៀកបំពាក់ហូល ផាមួង បានបង្ហាញនូវអត្តសញ្ញាណជាតិខ្មែរ៕

# ស្ត្រីគំរូក្នុងវិស័យកសិកម្ម



ខេត្តកែបជាតំបន់ទេចរណ៍ធម្មជាតិមួយនៃប្រទេសកម្ពុជា ប៉ុន្តែបើគិតពីសក្តានុពលចម្បងគឺវិស័យកសិកម្ម មានតាំងពីការដាំដុះ ដំណាំរួមផ្សំ ការចិញ្ចឹមសត្វ នេសាទ និងអនុផលព្រៃឈើ ប្រជាពលរដ្ឋនៅក្នុងខេត្តនេះភាគច្រើនប្រកបរបរធ្វើស្រែចំការ និងដាំដំណាំបន្ទាប់បន្សំទៅតាមរដូវ។

អ្នកស្រី **អ៊ូច ស៊ីណា** មានអាយុ២៨ឆ្នាំមានកូនស្រីម្នាក់ និងស្វាមីធ្វើការនៅមន្ទីរកសិកម្មខេត្ត។ ដើម្បីសម្រួលជីវភាពគ្រួសារអ្នកស្រីបានឆ្លៀតពេលធ្វើស្រែចំការ ដាំបន្លែ ចិញ្ចឹមត្រី និងចិញ្ចឹមជ្រូក តាំងពីមានតែប្រាំបីក្បាលរហូតដល់ចំនួន៦០ក្បាល។ ពេលជ្រូកមានកូនម្តងៗអ្នកស្រីទុកចិញ្ចឹមទាំងអស់។ អ្នកស្រីបានចូលរៀនបច្ចេកទេសកសិកម្ម ដូចជា ការជ្រើសរើសពូជជ្រូក ការថែទាំ ការធ្វើចំណី ការចាក់វ៉ាក់សាំង ចំពោះការចិញ្ចឹមមានរយៈពេលពី៣ខែទៅ ៤ខែចាប់ផ្តើមលក់ជ្រូកចេញ ក្នុងមួយក្បាលមានទម្ងន់ពី៦០ទៅ៧០គីឡូក្រាម ឯតម្លៃលក់ក្នុង ១ ក្បាល បាន៧០ ទៅ ៨០ម៉ឺនរៀល។

អ្នកស្រីបន្ថែមថា នៅពេលដែលចិញ្ចឹមបានហើយដល់ពេលលក់មិនពិបាករកទីផ្សារទេ គឺមានឈ្មួញមកទិញដល់កន្លែង ។ ប្រសិនបើជ្រូកនាំចូលពីក្រៅស្រុកច្រើន គឺខ្ញុំត្រូវរក្សាវាទុកសិនចាំពេលជ្រូកឡើងថ្លៃទើបលក់ចេញជាក្រោយ។ ចំពោះចំណីវិញ ខ្ញុំត្រូវយកស្រូវដែលបានពីការធ្វើស្រែ និងបន្លែដែលដាំបានហាលថ្ងៃឱ្យស្ងួត រួចយកទៅវៃធ្វើជាចំណីជ្រូក ដើម្បីកាត់បន្ថយការទិញចំណីពីខាងក្រៅ ។ ក្នុង១ឆ្នាំចំណាយដើមទុនវត្ថុធាតុដើមសរុប ១០លានរៀល រួមទាំងចំណីត្រីផងដែរ ប៉ុន្តែដោយសារមានម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនកិនស្រូវ ម៉ាស៊ីនវាយចំណីសត្វស្រាប់ ។

អ្នកស្រី **អ៊ូច ស៊ីណា** បានឱ្យដឹងទៀតថា រីឯការចិញ្ចឹមត្រីវិញ មានដីស្រះទំហំ ១២ម X ១២ម ផ្ទុកត្រីបាន ៦០គ.ក្រ រយៈពេលចិញ្ចឹមពី ៨ ទៅ ១០ខែ ទើបចាប់លក់បាន។ រីឯដីស្រែវិញមានទំហំ១ហិកតា ធ្វើស្រែបានផលពី ៥ ទៅ ៦តោនក្នុងមួយឆ្នាំ លក់បាន ៧-៨ លានរៀល។

អ្នកស្រីនិយាយទាំងញញឹមថា ចំពោះការចំណេញទាំងអស់សរុបទៅក្នុង១ឆ្នាំ ២០-៣០លានរៀល ខ្ញុំមានអារម្មណ៍រីករាយណាស់ ដោយសារការប្រកបរបរការងារកសិកម្មទទួលបានផលចំណេញច្រើនធ្វើឱ្យគ្រួសារមានជីវភាពធូរធា ។

នាងខ្ញុំសូមផ្តាំផ្ញើដល់កសិករទាំងឡាយ ជាពិសេសស្ត្រីកុំទុកពេលវេលាឱ្យទំនេរបន្ទាប់ធ្វើស្រែហើយ សូមងាកមករកការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និងដំណាំរួមផ្សំវាមានផលប្រយោជន៍ណាស់ សម្រាប់បង្កើនជីវភាពគ្រួសារ កូនរៀនបានខ្ពង់ខ្ពស់ បើមានចម្ងល់ត្រូវការឱ្យនាងខ្ញុំជួយពន្យល់ណែនាំ នាងខ្ញុំនឹងជួយដោយរីករាយ៕

## សកម្មភាពបរិច្ចាគឈាមរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅក្រសួងកិច្ចការនារី







គណៈប្រតិភូក្រសួងកិច្ចការនារីចុះសួរសុខទុក្ខកុមារកំព្រានៅខេត្តសៀមរាប



គណៈប្រតិភូក្រសួងកិច្ចការនារីថតរូបអនុស្សាវរីយ៍ជាមួយក្រុមបាល់ទាត់យុវជនក្រសួងកិច្ចការនារី

## សកម្មភាពដាំដើមឈើរបស់ក្រុមយុវជនក្រសួងកិច្ចការនារី





សកម្មភាពចុះសួរសុខទុក្ខ និងចែកសម្ភារៈសិក្សាដល់សិស្សានុសិស្ស នៅសាលាបឋមសិក្សា សង្កាត់ទៀន ក្នុងខេត្តកណ្ដាល។

## ក្រុមការងារបណ្ដាញយុវជនក្រសួងកិច្ចការនារី ចុះសួរសុខទុក្ខមន្ត្រីចូលនិវត្ត



លោកស្រី គង់ជី សុរីល



លោកស្រី ឯក វិរៈ

# លេខទូរស័ព្ទ ១៣ ខ្សែ សម្រាប់ស្វែងរកការសង្គ្រោះពេលជួបគ្រោះអាសន្ននៅប្រទេសម៉ាឡេស៊ី ប្រទេសចិន ប្រទេសថៃ:

ពលរដ្ឋខ្មែរយើងពេលជួបបញ្ហាសូមធ្វើការទំនាក់ទំនងជាមួយស្ថានទូត និងស្ថានអគ្គកុងស៊ុល កម្ពុជាប្រចាំនៅប្រទេសទាំងបីតាមលេខទូរស័ព្ទខាងក្រោម៖

## ១-ប្រទេសម៉ាឡេស៊ី៖

-ស្ថានឯកអគ្គរាជទូត: +៦០ ១១៣ ៣០៤ ៧៥៥ ៨

+៦០ ១០២ ៤៧១ ៩៨៦

## ២-ប្រទេសចិន៖

-ស្ថានឯកអគ្គរដ្ឋទូត: +៨៦ ១៨៨ ០១៤ ០៧៨ ៦៥

+៨៦ ១៨២ ០១៣ ៨២២ ៣៦

-ស្ថានអគ្គកុងស៊ុលនៅ ក្វាងចូវ: +៨៦ ១៣៩ ២៤១ ៧០០ ០៤

-ស្ថានអគ្គកុងស៊ុលនៅ ហុងកុង: +៨៥ ២៥៥ ៨៨៨ ៥៨៩

+៨៥ ២៦៥ ១៦៦ ៦៧៨

-ស្ថានអគ្គកុងស៊ុលនៅ សៀងហៃ: +៨៦ ១៥៦ ០១៧ ១៨៧ ៧៧

-ស្ថានអគ្គកុងស៊ុលនៅ ឆុងឈីង: +៨៦ ១៣៦ ២៨៤ ៩៦១ ៩៣

-ស្ថានអគ្គកុងស៊ុលនៅ គន់មីង: +៨៦ ១៣៧ ៩៥១ ៩២៣ ៩៨

-ស្ថានអគ្គកុងស៊ុលនៅ ណាននីង: +៨៦ ១៨២ ៧៦៦ ៧៧៧ ៧៨

## ៣-ប្រទេសថៃ:

-ស្ថានឯកអគ្គរាជទូត: +៦៦ ៩៨៤ ០៤១ ៥៥០

-ស្ថានអគ្គកុងស៊ុលនៅ សាកែវ: +៦៦ ៦១៧ ៦៨៨ ៧០៦